# អនុសញ្ញាអាស៊ានប្រឆាំងនឹងអំពើជួញដូរមនុស្ស ជាពិសេស ស្ត្រី និងកុមារ

រដ្ឋជាសមាជិកទាំងអស់នៃសមាគមន៍បណ្តាប្រជាជាតិនៅអាស៊ីអគ្នេយ៍( ដែលហៅកាត់ថា" ***អាស៊ាន***"រួមមាន : **ព្រុយណេដារូសាឡឹម ព្រះរាជាណាចក្រកម្ពុជា សាធារណរដ្ឋឥណ្ឌូណេស៊ី សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ ម៉ាឡេស៊ី សាធារណរដ្ឋសហភាពមីយ៉ានម៉ា សាធារណរដ្ឋភីលីពីន សាធារណរដ្ឋសឹង្ហបូរី ព្រះរាជាណាចក្រថៃ** និង**សាធារណរដ្ឋសង្គមនិយមវៀតណាម** ជាឯកត្តនាមហៅថា **"*ភាគី*"** និង ជាសមូហនាមហៅថា **"*ភាគីទាំងអស់*"**

***ដោយទទួលស្គាល់ថា*** អំពើជួញដូរមនុស្សគឺជាការរំលោភលើសិទ្ធិមនុស្ស និងជាការប្រមាថដល់សេចក្តីថ្លៃថ្នូររបស់មនុស្សជាតិ ។

***ដោយរំលឹកឡើងវិញ*** ពីគោលបំណង និង **បណ្តាគោលការណ៏នៃធម្មនុញ្ញរបស់សហប្រជាជាតិ សេចក្តីប្រកាសជាសាកល ស្តីពីសិទ្ធិមនុស្ស "ធម្មនុញ្ញរបស់អាស៊ាន" សេចក្តីប្រកាសរបស់អាស៊ាន ស្តីពីសិទ្ធិមនុស្ស អនុសញ្ញាសហប្រជាជាតិប្រឆាំងនឹងឧក្រឹដ្ឋកម្មឆ្លងដែនដែលមានអង្គការចាត់តាំង** ហើយដែលត្រូវយកមកអនុវត្តផងដែរ នោះគឺ**ពិធីសារ ដើម្បីបង្ការ-ទប់ស្កាត់ បង្ក្រាប និង ផ្តន្ទាទោសអំពើជួញដូរមនុស្ស ជាពិសេសស្ត្រី និង កុមារ ព្រមទាំងបណ្តាកិច្ចព្រមព្រៀង** និង **បណ្តាសេចក្តីសំរេចចិត្តនានារបស់សហប្រជាជាតិ ស្តីពី ការលុបបំបាត់អំពើជួញដូរមនស្ស** និងដើម្បីលើកស្ទួយ និង ការពារសិទ្ធិមនុស្ស សេរីភាពជាមូលដ្ឋាន ប្រព្រឹត្តកម្មត្រឹមត្រូវ នីតិរដ្ឋ និង នីតិវិធីត្រឹមត្រូវ ។

***ដោយបញ្ជាក់អះអាងសារជាថ្មី*** នូវការប្តេជ្ញាចិត្តរបស់យើងចំពោះ**ធម្មនុញ្ញអាស៊ាន** ក្នុងគោលបំណងឆ្លើយតបប្រកបដោយប្រសិទ្ធិភាពទៅនឹងរាល់ទម្រង់នៃឧក្រិដ្ឋកម្មឆ្លងដែន និង រាល់ញ្ហាប្រឈមឆ្លងដែននានា ស្របតាមគោលការណ៏សន្តិសុខដ៏ពេញលេញ ។

***ដោយបញ្ជាក់អះអាងសារជាថ្មីផងដែរ***

នូវការប្តេជ្ញាចិត្តរបស់យើងចំពោះ***សេចក្តីប្រកាសអាស៊ានប្រឆាំងនឹងអំពើជួញដូរមនុស្ស ជាពិសេសស្ត្រី និងកុមារ***ដែលបានអនុម័តកាលពីឆ្នាំ ២០០៤ ***ការឆ្លើយតបផ្នែកយុត្តិ ធម្មព្រហ្មទណ្ឌទៅនឹងអំពើជួញដូរមនុស្សៈ បញ្ចប់និទណ្ឌភាពសំរាប់ពួកជួញដូរមនុស្ស និងធានាផ្តល់យុត្តិធម៌ជូនជន រងគ្រោះឆ្នាំ ២០០៧ "គោលការណ៏ណែនាំអាស៊ានសំរាប់អ្នកអនុវត្តផ្ទាល់" សេចក្តីថ្លែងការណ៏រួមរបស់ប្រមុខដឹក នាំអាស៊ាន ស្តីពីការលើកកំពស់កិច្ចសហប្រតិបត្តិការប្រឆាំងនឹងអំពើជួញដូរមនុស្សនៅអាស៊ីអាគ្នេយ៍ឆ្នាំ ២០១១ និងកិច្ចប្រឹងប្រែងនានារបស់អាស៊ានដើម្បី***

***លើកស្ទួយសិទ្ធិមនុស្ស រួមទាំងសេចក្តីប្រកាសអាស៊ាន ស្តីពី សិទ្ធិមនុស្ស ដែលបានអនុម័តកាលពីឆ្នាំ ២០១២។***

***ដោយបញ្ជាក់អះអាងសារជាថ្មីបន្ថែមទៀត*** នូវការប្តេជ្ញាចិត្តរបស់យើងក្នុងការពង្រឹងកិច្ចសហប្រតិបត្តិការតំបន់ និង អន្តរជាតិឱ្យកាន់តែខ្លាំងក្លា និង មានប្រសិទ្ធិភាពថែមទៀត ដើម្បីប្រឆាំងនឹងអំពើជួញដូរមនុស្ស ដែលមានចរិតជាបទល្មើសឆ្លងដែន ដោយក្នុងនោះមិនសំដៅទៅលើតែបទល្មើសដែលប្រព្រឹត្តដោយក្រុមឧក្រិដ្ឋជន ដែលមានអង្គការចាត់តាំងនោះឡើយ។

***ដោយទទួលស្គាល់ថា*** កិច្ចសហប្រតិបត្តិការគឺជាប្រការចាំបាច់បំផុតដែលនាំឱ្យការស៊ើបអង្កេត ការផ្តន្ទាទោស និង ការលុបបំបាត់ប្រកបដោយជោគជ័យនូវទីជម្រកសុវត្ថិភាពសម្រាប់ជនប្រព្រឹត្តបទល្មើស និង ពួកជនសមគំនិតក្នុងអំពើជួញដូរមនុស្ស ក៏ដូចជាដើម្បីការពារ និងជួយដល់ជនរងគ្រោះយ៉ាងមានប្រសិទ្ធិភាព។

***ដោយទទួលស្គាល់ថា*** អំពើជួញដូរមនុស្សបង្កឡើងដោយកត្តារួមផ្សំជាច្រើន ក្នុងនោះរួមមានអំពើពុករលួយរបស់រដ្ឋាភិបាល ភាពក្រីក្រ អស្ថិរភាពសេដ្ឋកិច្ច ប្រព័ន្ធច្បាប់គ្មានប្រសិទ្ធិភាព ឧក្រិដ្ឋកម្មដែលមានអង្គការចាត់តាំង និង តម្រូវការដែលផ្គត់ផ្គង់ដល់រាល់ទម្រង់នៃការធ្វើអាជីវកម្មលើមនុស្ស ជាពិសេសស្ត្រី និង កុមារ ដែលនាំឱ្យមានអំពើជួញដូរមនុស្ស ហើយចាំបាច់ត្រូវតែចាត់វិធានការដោះស្រាយឱ្យមានប្រសិទ្ធិភាព ។

***ដោយយល់ឃើញថា*** បណ្តារដ្ឋជាសមាជិកអាស៊ាន មិនចំពោះថា រដ្ឋដែលជាប្រទេសប្រភព ប្រទេសឆ្លងកាត់ ឬជាប្រទេសគោលដៅនោះឡើយ គឺសុទ្ធតែមានការទទួលខុសត្រូវរួម និង មានគោលបំណងរួមដូចគ្នា ដើម្បីបង្ការ- ទប់ស្កាត់អំពើជួញដូរមនុស្ស ការផ្តន្ទាទោស និងដាក់ទណ្ឌកម្មដល់ជនល្មើសនៃអំពើជួញដូរមនុស្ស ព្រមទាំងត្រូវការពារ និង ជួយដល់ជនរងគ្រោះដោយអំពើជួយដូរមនុស្ស។

***ដោយគិតពិចារណាដល់*** ភាពជាអ្នកជិតខាង និងមានព្រំដែនជាប់គ្នានៃបណ្តារដ្ឋជាសមាជិកអាស៊ាន និង ដោយឈរលើស្មារតីតំបន់និយម។

***ដោយទទួលស្គាល់*** ពីភាពចាំបាច់ដើម្បីបង្កើតឱ្យមានលិខិតុបករណ៍តំបន់ ដែលជាក្របខ័ណ្ឌច្បាប់សំរាប់ប្រឈមដោះស្រាយជាពិសេសជាមួយនឹងអំពើជួញដូរមនុស្ស និង ដើម្បីធ្វើសកម្មភាពថ្នាក់តំបន់ក្នុងការបង្ការ-ទប់ស្កាត់ និង ប្រយុទ្ធប្រឆាំងនឹងអំពើជួញដុរមនុស្ស ដែលក្នុងនោះរួមមានទាំងកិច្ចការពារ និងជួយដល់ជនរងគ្រោះដោយអំពើជួញដូរមនុស្ស។

***ដោយទទួលស្គាល់*** ពីសារៈសំខាន់ដែលត្រូវរៀបចំឱ្យមានលិខិតុបករណ៍តំបន់ប្រឆាំងនឹងអំពើជួញដូរមនុស្ស ដែលមានតម្លៃផ្លូវច្បាប់ ហើយដែលនឹងជួយដល់បណ្តារដ្ឋជាសមាជិកអាស៊ានក្នុងការចាត់វិធានការដោះស្រាយរាល់បញ្ហា

ប្រឈម   បណ្តាអាទិភាពនានា   និង បណ្តាយុទ្ធសាស្រ្តផ្សេងៗរបស់ប្រទេសផងខ្លួនក្នុងការប្រយុទ្ធប្រឆាំងនឹងអំពើជួញដូរមនុស្ស  ក្នុងនាមជាប្រទេសប្រភព ប្រទេសឆ្លងកាត់  ឬ ជាប្រទេសគោលដៅ ។

***បានឯកភាពគ្នាដូចតទៅនេះ:***

## ជំពូក I

## បទបញ្ញត្តិទូទៅ

### មាត្រា I

### គោលបំណង

១-លិខិតុបករណ៍ច្បាប់តំបន់នេះមានគោលបំណង :

ក-ដើម្បីបង្ការ-ទប់ស្កាត់ និង ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សប្រកបដោយប្រសិទ្ធិភាព ជាពិសេសស្ត្រី និង កុមារ និង ដើម្បីធានាការដាក់ទណ្ឌកម្មលើជនជួញដូរប្រកបដោយយុត្តិធម៌ និង មានប្រសិទ្ធិភាព។

ខ-ដើម្បីការពារ និង ជួយដល់ជនរងគ្រោះដោយអំពើជួញដូរមនុស្ស     ដោយគោរពយ៉ាងពេញលេញដល់ដល់សិទ្ធិមនុស្សរបស់ពួកគេ និង

គ-ដើម្បីលើកកំពស់កិច្ចសហប្រតិបត្តិការនៅក្នុងចំណោមរដ្ឋជាភាគីទាំងអស់សំដើម្បីសំរេចបានគោលបំណងនេះ ។

២-ភាគីទាំងអស់បានព្រមព្រៀងគ្នាថា    បណ្តាវិធានការដែលមានចែងលំអិតនៅក្នុងអនុសញ្ញានេះត្រូវតែមានការបកស្រាយបានច្បាស់លាស់  និង    ត្រូវអនុវត្តឱ្យបានសមស្របតាមបណ្តាគោលការណ៍ដែលមានការទទួលស្គាល់ជាលក្ខណៈអន្តរជាតិ និង តំបន់ ស្តីពី ភាពមិនរើសអើង ជាពិសេសចំពោះបុគ្គលទាំងឡាយណា ដោយសំអាងលើហេតុផលថា ពួកគេជាជនរងគ្រោះដោយអំពើជួញដូរមនុស្ស ។

### មាត្រា   ២

### ការប្រើពាក្យពេចន៍

***អនុសញ្ញានេះមានគោលបំណង:***

ក. “អពើជួញដូរមនុស្ស”  មានន័យថា  ការជ្រើសរើស  ការដឹកជញ្ជូន  ការផ្ទេរ  ការផ្តល់កន្លែងឱ្យជ្រកកោន ឬការទទួលយកមនុស្ស តាមរយៈមធ្យោបាយនៃការគំរាមកំហែង ឬការប្រើកំលាំង  ឬ

ទម្រង់ផ្សេងទៀតនៃការបង្ខិតបង្ខំ ការចាប់ពង្រត់ ការឆបោក ការបោកបញ្ឆោត ការរំលោភសិទ្ធិអំណាច ឬ ស្ថានភាពដែលងាយរងគ្រោះ ឬ ការប្រគល់ ឬ ទទួលយកកម្រៃ/ប្រាក់ ឬ ផលប្រយោជន៍នានា ដើម្បីទទួលបានការយល់ព្រមរបស់បុគ្គលម្នាក់ដែលកំពុងគ្រប់គ្រងលើបុគ្គលម្នាក់ទៀត ក្នុងគោលបំណងធ្វើអាជីវកម្ម។ ជាកម្រិតអប្បបរមា ការធ្វើអាជីវកម្មត្រូវរួមបញ្ចូលការធ្វើអាជីវកម្មលើអំពើពេស្យាចាររបស់អ្នកដទៃ ឬ ទម្រង់ផ្សេងទៀតនៃអំពើធ្វើអាជីវកម្មផ្លូវភេទ ពលកម្ម ឬ បណ្តាសេវាកម្មបង្ខិតបង្ខំ ទាសភាព ឬ ការអនុវត្តទាំងឡាយណាដែលមានលក្ខណៈប្រហាក់ប្រហែលនឹងទាសភាព សេវគតិភាព ឬ ការដកហូតសរីរាង្គ។

ខ. ការយល់ព្រមរបស់ជនរងគ្រោះដោយអំពើជួញដូរមនុស្សទៅនឹងគោលបំណងនៃការធ្វើអាជីវកម្ម ដែលមានចែងនៅក្នុងអនុកថាខ័ណ្ឌ(ក) នៃមាត្រានេះនឹងមិនអាចយកជាការបានទេ ប្រសិនបើមធ្យោបាយណាមួយដែលមានចែងនៅក្នុងអនុកថាខ័ណ្ឌ(ក) នេះត្រូវបានយកមកប្រើប្រាស់។

គ. ការជ្រើសរើស ការដឹកជញ្ជូន ការផ្ទេរ ការផ្តល់កន្លែងជ្រកកោន ឬ ការទទួលយកកុមារក្នុងគោលបំណងធ្វើអាជីវកម្ម ត្រូវចាត់ទុកថាជា "អំពើជួញដូរមនុស្ស" បើទោះជាមិនមានការពាក់ព័ន្ធដល់មធ្យោបាយណាមួយដូចមានចែងនៅក្នុងអនុកថាខ័ណ្ឌ(ក) នៃមាត្រានេះក៏ដោយ។

ឃ. និយមន័យនៃ "កុមារ" គឺបុគ្គលដែលមានអាយុក្រោម ១៨ឆ្នាំ។

ង. ជនរងគ្រោះមានន័យថា ជារូបវន្តបុគ្គលដែលជាកម្មវត្ថុនៃអំពើជួញដូមនុស្សដូចបានកំណត់នៅក្នុងអនុសញ្ញានេះ។

ច. "ក្រុមឧក្រិដ្ឋជនដែលមានអង្គការចាត់តាំង" (តាមនិយមន័យរបស់ **UNTOC**) មានន័យថា គឺជាក្រុមមួយដែលមានរចនាសម្ព័ន្ធ មានគ្នាចាប់ពីបីនាក់ ឬ ច្រើនជាងនេះ មានវត្តមាននៅក្នុងពេលវេលាណាមួយ ឬនិងធ្វើសកម្មភាពដោយស្រុះស្រួលគ្នា ក្នុងគោលបំណងប្រព្រឹត្តបទឧក្រិដ្ឋធ្ងន់ធ្ងរម្តង ឬ ច្រើនជាងម្តង ឬបទល្មើសទាំងឡាយណា ដើម្បីទទួលបានដោយផ្ទាល់ ឬដោយប្រយោលនូវផលប្រយោជន៍ហិរញ្ញវត្ថុ ឬ ផលប្រយោជន៍ជាសំភារៈ/ជាសារវន្តផ្សេងទៀត ដូចមានចែងស្របតាមអនុសញ្ញានេះ។

ឆ. "បទឧក្រិដ្ឋធ្ងន់ធ្ងរ" ដូចមានចែងនៅក្នុងកថាខ័ណ្ឌ(ច) នៃមាត្រានេះមានន័យថា ជាអំពើប្រព្រឹត្តដែលនាំឱ្យកើតបទល្មើស ហើយដែលអាចផ្តន្ទាទោសបាន តាមរយៈការដកហូតសេរីភាពជាអតិ

ឬបរមាយ៉ាងតិចបំផុតរយៈពេល ០៤ឆ្នាំ ឬ ត្រូវទទួលទោសធ្ងន់ជាងនេះ ។

ជ. "ឧក្រិដ្ឋកម្មឆ្លងដែន"ជាបទល្មើសដែលមានចរិតឆ្លងដែន ។បទល្មើសដែលមានចរិតឆ្លងដែន កាលបើៈ

**(i)** បទល្មើសដែលត្រូវបានប្រព្រឹត្តឡើងនៅក្នុងរដ្ឋចាប់ពីពីរឡើងទៅ

**(ii)** បទល្មើសត្រូវបានប្រព្រឹត្តឡើងនៅក្នុងរដ្ឋតែមួយ ក៏ប៉ុន្តែការត្រៀមរៀបចំមួយផ្នែកធំការធ្វើផែនការ ការដឹកនាំបញ្ជា ឬ ការគ្រប់គ្រងកើតឡើងនៅក្នុងរដ្ឋមួយផ្សេងទៀត ។

**(iii)** បទល្មើសត្រូវបានប្រព្រឹត្តឡើងនៅក្នុងរដ្ឋតែមួយ ប៉ុន្តែមានការពាក់ព័ន្ធដល់ក្រុមឧក្រិដ្ឋជនដែលមានអង្គការចាត់តាំង និងដែលធ្វើសកម្មភាពឧក្រិដ្ឋនៅក្នុងរដ្ឋចាប់ពីពីរឡើងទៅ ឬ

**(iv)** បទល្មើសត្រូវបានប្រព្រឹត្តឡើងនៅក្នុងរដ្ឋតែមួយ ប៉ុន្តែមានផលប៉ះពាល់ជាដុំកំភួនដល់រដ្ឋមួយទៀត ។

i- “មន្ត្រីសាធារណៈ” មានន័យថា ៈ

(i) ជាបុគ្គលដែលកំពុងកាន់មុខតំណែងនីតិបញ្ញត្តិ នីតិប្រតិបត្តិ រដ្ឋបាល ឬ តុលាការនៃភាគីមួយ ទោះត្រូវបានតែងតាំង ឬ តាមរយៈការបោះឆ្នោតជ្រើសរើសក្តី ទោះជាអចិន្ត្រៃយ៍ ឬ ជាបណ្តោះអាសន្នក្តី ទោះជាទទួលបានប្រាក់បៀវត្សរ៍ ឬ មិនបានទទួលក្តី ដោយមិនគិតអំពីអតីតភាពរបស់បុគ្គលនោះឡើយ ។

(ii) បុគ្គលដទៃទៀតដែលបំពេញមុខងារសាធារណៈ ក្នុងនោះគិតទាំងទីភ្នាក់ងារសាធារណៈ ឬ សហគ្រាសសាធារណៈ ឬ ក៏ផ្តល់សេវាសាធារណៈ ដូចមានកំណត់នៅក្នុងច្បាប់ប្រទេសនៃភាគី និងដូចត្រូវបានអនុវត្តនៅក្នុងផ្នែកពាក់ព័ន្ធនៃច្បាប់របស់ភាគីនោះ ។

(iii) បុគ្គលដទៃទៀតដែលត្រូវបានកំណត់ថាជា “មន្ត្រីសាធារណៈ” នៅក្នុងច្បាប់ប្រទេសនៃភាគីនោះ ។

ញ-“ទ្រព្យសម្បត្តិ” មានន័យថា ជាទ្រព្យគ្រប់ប្រភេទ ទោះជាមានរូបរាង ឬ គ្មានរូបរាងក្តី ជាចលនៈទ្រព្យ ឬ ជាអចលនៈទ្រព្យក្តី ជារូបទ្រព្យ ឬ ជាអរូបទ្រព្យក្តី និង ឯកសារ ឬ លិខិតុបករណ៍ផ្លូវច្បាប់ ដែលបញ្ជាក់ពីកម្មសិទ្ធិលើទ្រព្យ ឬ ផលប្រយោជន៍ទាំងនេះ ។

ដ “ផលចំណូលនៃបទល្មើស” មានន័យថា ជាទ្រព្យសម្បត្តិដែលកើតចេញពី ឬ ទទួលបានមកតាម

រយៈការប្រព្រឹត្តិបទល្មើសមួយ ទោះជាផលចំណូលនេះទទួលបានមកដោយផ្ទាល់ ឬ ដោយប្រយោលក្តី ។

ឋ.“ការបង្កក” ឬ “ការដកហូត” មានន័យថា ការហាមឃាត់ជាបណ្តោះអាសន្នមិនឱ្យមានការផ្ទេរការដោះដូរ ការចាត់ចែង ឬ ការបំលាស់ទីទ្រព្យសម្បត្តិ ឬ ជាការទទួលយកមករក្សាទុក ឬ អភិបាលជាបណ្តោះអាសន្ន ដោយផ្អែកលើដីកាដែលចេញដោយតុលាការ ឬ អាជ្ញាធរផ្សេងទៀតដែលមានសមត្ថកិច្ច ។

ឌ.“ការរឹបអូស”រួមបញ្ចូលទាំងការដកហូត-ក្នុងករណីដែលអាចអនុវត្តបាន- មានន័យថាជាការដកហូតយកទ្រព្យសម្បត្តិជាអចិន្ត្រៃយ៍តាមដីការបស់តុលាការ ឬ អាជ្ញាធរផ្សេងទៀតដែលមានសមត្ថកិច ។

ឍ. “បទល្មើសសំអាង”មានន័យថាជាបទល្មើសទាំងឡាយណា ដែលបង្កើតបានជាផលចំណូល ដែលផលចំណូលនេះអាចក្លាយជាកម្មវត្ថុនៃបទល្មើសដូចមានកំណត់នៅក្នុងមាត្រា៧នៃអនុសញ្ញានេះ ។

## មាត្រា ៣

## វិសាលភាពនៃការអនុវត្ត

អនុសញ្ញានេះនឹងត្រូវយកមកអនុវត្តសម្រាប់ការបង្ការ-ទប់ស្កាត់ ការស៊ើបអង្កេត និងការផ្តន្ទាទោសបទល្មើសដែលបានកំណត់អនុលោមតាមមាត្រា ៥ នៃអនុសញ្ញានេះ ហើយដែលបទល្មើសទាំងនោះមានចរិតជាបទល្មើសឆ្លងដែន រួមមានបទល្មើសប្រព្រឹត្តឡើងដោយក្រុមឧក្រិដ្ឋជន ដែលមានអង្គការចាត់តាំង ក៏ដូចជាកិច្ចការពារ និងផ្តល់ជំនួយដល់ជនរងគ្រោះដោយអំពើជួញដូរមនុស្ស ។

## មាត្រា ៤

## ការការពារអធិបតេយ្យភាព

១. ភាគីទាំងអស់ត្រូវអនុវត្តកាតព្វកិច្ចរបស់ខ្លួនដែលមានចែងនៅក្នុងអនុសញ្ញានេះឱ្យបានសមស្របទៅតាមបណ្តាគោលការណ៍ ស្តីពីសមភាពនៃអធិបតេយ្យភាព និងបូរណភាពដែនដីនៃរដ្ឋទាំងអស់ និងត្រូវប្រកាន់នូវបណ្តាគោលការណ៍ ស្តីពីការមិនជ្រៀតជ្រែកកិច្ចការផ្ទៃក្នុងរបស់រដ្ឋដទៃ ។

២. នៅក្នុងអនុសញ្ញានេះពុំបានផ្តល់សិទ្ធិដល់រដ្ឋជាភាគីមួយ ដើម្បីប្រើប្រាស់យុត្តធិការ និង បំពេញមុខនាទីនៅក្នុង

ដែនដីរបស់ភាគីមួយទៀតឡើយ ដែលអំណាច និង សមត្ថកិច្ចនានាត្រូវបានរក្សាសិទ្ធិផ្ដាច់មុខដោយច្បាប់ផ្ទៃក្នុងរបស់ភាគីមួយនោះ។

## ជំពូក II

## ការចាត់ទុកជាអំពើល្មើសច្បាប់ព្រហ្មទណ្ឌ

### មាត្រា ៥

### ការចាត់ទុកជាអំពើជួញដូរមនុស្សជាអំពើល្មើសច្បាប់ព្រហ្មទណ្ឌ

១. ភាគីនីមួយៗត្រូវអនុម័តបណ្ដាវិធានការច្បាប់ និងបណ្ដាវិធានការចាំបាច់ផ្សេងទៀតដើម្បីចាត់ទុកថាជាបទល្មើសព្រហ្មទណ្ឌនូវអំពើប្រព្រឹត្តដូចមានចែងនៅក្នុងមាត្រា ២ នៃអនុសញ្ញានេះ កាលបើបទល្មើសទាំងនេះត្រូវបានប្រព្រឹត្តឡើងដោយចេតនា។

២.ភាគីនីមួយៗក៏ត្រូវអនុម័តបណ្ដាវិធានការច្បាប់ និងបណ្ដាវិធានការចាំបាច់ផ្សេងទៀត ដើម្បីចាត់ទុកជាបទល្មើសព្រហ្មទណ្ឌនូវៈ

ក.អាស្រ័យដោយគោលគំនិតមូលដ្ឋាននៃប្រព័ន្ធច្បាប់របស់ខ្លួន ចំពោះការប៉ុនប៉ងប្រព្រឹត្តបទល្មើសដូចមានចែងអនុលោមតាមកថាខ័ណ្ឌ ១ នៃមាត្រានេះ។

ខ. ការចូលរួមក្នុងនាមជាអ្នកសមគំនិតនៅក្នុងបទល្មើស ដូចមានចែងអនុលោមតាមកថាខ័ណ្ឌ១ នៃមាត្រានេះ។

គ. ការរៀបចំ-ចាត់ចែង ឬ ការដឹកនាំ-បញ្ជាអ្នកដទៃឱ្យប្រព្រឹត្តបទល្មើស ដូចមានចែងអនុលោមតាមកថាខ័ណ្ឌ ១ នៃមាត្រានេះ។

៣. ភាគីនីមួយៗត្រូវអនុម័តបណ្ដាវិធានការច្បាប់ និងបណ្ដាវិធានការសមស្របផ្សេងទៀត ដើម្បីឱ្យជនល្មើសទទួលទោសខ្ពស់ជាងទោសធម្មតា ប្រសិនបើមានស្ថានទម្ងន់ទោសដូចខាងក្រោមនេះ

ក. បទល្មើសដែលពាក់ព័ន្ធដល់ការបង្កឱ្យមានរបួសធ្ងន់ធ្ងរ ឬ បណ្ដាលឱ្យជនរងគ្រោះ ឬ ជនណាម្នាក់ទៀតស្លាប់ ដោយក្នុងនោះគិតទាំងការស្លាប់ដោយការធ្វើអត្តឃាតផងដែរ។

ខ- បទល្មើសដែលពាក់ព័ន្ធដល់ជនរងគ្រោះ ដែលងាយទទួលរងគ្រោះជាពិសេស ដូចជា កុមារ ឬ បុគ្គលដែលមិនមានលទ្ធភាពថែរក្សាខ្លួន ឬ ការពារខ្លួនឯងបាន ដោយសារតែស្ថានភាព ឬ ពិការភាពទាំងផ្លូវកាយ និងផ្លូវចិត្ត។

គ- បទល្មើសដែលបណ្តាលឱ្យជនរងគ្រោះទទួលនូវជម្ងឺគំរាមកំហែងដល់អាយុជីវិត រួមមាន ហ៊ីវ/អេដស៍ ជាដើម ។

ឃ-បទល្មើសដែលពាក់ព័ន្ធដល់ជនរងគ្រោះចាប់ពីពីរនាក់ឡើងទៅ ។

ង- បទល្មើសដែលបានប្រព្រឹត្តឡើងនោះ គឺជាផ្នែកមួយនៃសកម្មភាពរបស់ក្រុមឧក្រិដ្ឋជនដែលមានអង្គការចាត់តាំង ។

ច- ជនល្មើសធ្លាប់ត្រូវបានកាត់ទោសពីបទល្មើសដដែល ឬ បទល្មើសស្រដៀងគ្នានេះពីមុនមក ។

ឆ-បទល្មើសដែលប្រព្រឹត្តឡើងដោយមន្ត្រីសាធារណៈ ក្នុងពេលដែលកំពុងតែបំពេញករណីយកិច្ចសាធារណៈរបស់ខ្លួន ។

## មាត្រា ៦

## ការចាត់ទុកជាអំពើល្មើសច្បាប់ព្រហ្មទណ្ឌចំពោះការ ចូលរួមនៅក្នុងក្រុមឧក្រិដ្ឋជនដែលមានអង្គការចាត់តាំង

១. ទាក់ទងទៅនឹងបណ្តាបទល្មើសទាំងឡាយដែលមានចែងនៅក្នុងមាត្រា ៣ នៅក្នុងអនុសញ្ញានេះ ភាគីនីមួយៗត្រូវអនុម័តបណ្តាវិធានការច្បាប់ និង បណ្តាវិធានការចាំបាច់ផ្សេងទៀត ដើម្បីចាត់ទុកជាបទល្មើសព្រហ្មទណ្ឌនៅពេលដែលអំពើជួញដូរមនុស្សត្រូវបានប្រព្រឹត្តឡើងដោយចេតនា :

**ក**- តែបទល្មើសណាមួយ ឬ បទល្មើសទាំងពីរខាងក្រោមនេះ ដែលខុសពីបទល្មើសទាំងឡាយដែលពាក់ព័ន្ធនឹងការប៉ុនប៉ងប្រព្រឹត្តសកម្មភាពល្មើស ឬ ការប្រព្រឹត្តសកម្មភាពល្មើសបានចប់សព្វគ្រប់:

(i)-ព្រមព្រៀងជាមួយនឹងនរណាម្នាក់ ឬ បុគ្គលច្រើននាក់ផ្សេងទៀត ដើម្បីប្រព្រឹត្តបទឧក្រិដ្ឋធ្ងន់ធ្ងរដោយមានគោលបំណងទាក់ទងទៅនឹងការទទួលបានដោយផ្ទាល់ ឬ ដោយប្រយោលក្តី នូវផលប្រយោជន៍ហិរញ្ញវត្ថុ ឬ ផលប្រយោជន៍ជាសំភារៈផ្សេងទៀត និងមានការពាក់ព័ន្ធទៅនឹងអំពើដែលប្រព្រឹត្តដោយអ្នកចូលរួមម្នាក់ក្នុងចំណោមអ្នកចូលរួមឯទៀត សំដៅជួយជ្រោមជ្រែងឱ្យកិច្ចព្រមព្រៀងនេះមានភាពជឿនលឿនទៅមុខ ឬ មានការពាក់ព័ន្ធជាមួយនឹងក្រុមឧក្រិដ្ឋជនដែលមានអង្គការចាត់តាំង នេះអាស្រ័យដោយច្បាប់របស់ប្រទេសតម្រូវ ។

(ii)-ការប្រព្រឹត្តដោយបុគ្គលម្នាក់ ដែលបានដឹងអំពីគោលបំណង និង ទាំងសកម្មភាពទូទៅរបស់ក្រុមឧក្រិដ្ឋជនដែលមានអង្គការចាត់តាំង ឬ ចេតនារបស់ក្រុមនេះ ដើម្បីប្រព្រឹត្តបទល្មើសដែលកំពុង

តែនិយាយដល់ ហើយបានចូលរួមចំណែកយ៉ាងសកម្មនៅក្នុង :

(ក)-បណ្ដាសកម្មភាពប្រព្រឹត្តបទល្មើសរបស់ក្រុមឧក្រិដ្ឋជនដែលមានអង្គការចាត់តាំង ។

(ខ)-បណ្ដាសកម្មភាពផ្សេងទៀតរបស់ក្រុមឧក្រិដ្ឋជនដែលមានអង្គការចាត់តាំង ដោយបានដឹងថា ការចូលរួមរបស់ខ្លួនមុខជានឹងរួមចំណែកជួយឱ្យសំរេចបាននូវគោលបំណងនៃបទល្មើស ដូចបានរៀបរាប់ខាងលើ ។

**ខ**-រៀបចំចាត់ចែង ដឹកនាំបញ្ជា ជួយជ្រោមជ្រែង ជួយលើកទឹកចិត្ត ជួយសម្របសម្រួល ឬ ជួយផ្ដល់យោបល់ដល់ការប្រព្រឹត្តបទល្មើសធ្ងន់ធ្ងរពាក់ព័ន្ធនឹងក្រុមឧក្រិដ្ឋជនដែលមានអង្គការចាត់តាំង ។

**២**-ការដឹងឮ ចេតនា បំណង គោលបំណង ឬ ការព្រមព្រៀង យោងតាមកថាខ័ណ្ឌ ១នៃមាត្រានេះ អាចជាការទាញការសន្និដ្ឋានពីកាលៈទេសៈពិតដោយឥតលំអៀង ។

## មាត្រា ៧

## ការចាត់ទុកការសំអាតផលចំណូលនៃបទល្មើសជាអំពើល្មើសច្បាប់ព្រហ្មទណ្ឌ

ទាក់ទងទៅនឹងបណ្ដាបទល្មើសទាំងឡាយ ដូចមានចែងនៅក្នុងមាត្រា ៣ នៃអនុសញ្ញានេះ ភាគីនីមួយៗ ដោយអនុលោមតាមបណ្ដាគោលការណ៍ជាមូលដ្ឋាននៃច្បាប់របស់ប្រទេសខ្លួន ត្រូវអនុម័តច្បាប់ និងបណ្ដាវិធានការចាំបាច់ផ្សេងទៀតដើម្បីចាត់ទុកជាអំពើល្មើសច្បាប់ព្រហ្មទណ្ឌចំពោះការប្រព្រឹត្តដូចមានចែងនៅក្នុងមាត្រា ៣ នៃអនុសញ្ញានេះ កាលបើបទល្មើសទាំងនេះត្រូវបានប្រព្រឹត្តឡើងដោយចេតនា :

ក-(i) ការដោះដូរ ការផ្ទេរទ្រព្យសម្បត្តិ ដោយខ្លួនបានដឹងថា ទ្រព្យសម្បត្តិនោះគឺជាផលចំណូលនៃបទល្មើស ក្នុងគោលបំណងបិទបាំង ឬ បំភាន់អំពីប្រភពដើមខុសច្បាប់នៃទ្រព្យសម្បត្តិ ឬ ជួយដល់ជនណាម្នាក់ ដែលមានការពាក់ព័ន្ធក្នុងការប្រព្រឹត្តបទល្មើសជាសំអាងដើម្បីគេចវេសពីបច្ច័យអាក្រក់ផ្លូវច្បាប់ចំពោះទង្វើរបស់ខ្លួន ។

(ii) ការបិទបាំង ឬ ការបំភាន់អំពីសភាពពិត ប្រភព ទីកន្លែង ការចាត់ចែង ការបំលាស់ទី ឬ កម្មសិទ្ធិនៃ ឬ សិទ្ធិដែលទាក់ទងនឹងទ្រព្យសម្បត្តិ ដោយបានដឹងថា ទ្រព្យសម្បត្តិទាំងនេះគឺជាផលចំណូលនៃបទល្មើស ។

**ខ**-អាស្រ័យដោយគោលគំនិតមូលដ្ឋាននៃប្រព័ន្ធច្បាប់របស់ខ្លួន :

(i) ការទទួលបានមក ការកាន់កាប់ ឬ ការប្រើប្រាស់នូវទ្រព្យសម្បត្តិ ដោយនៅពេលដែលទទួលមក

នោះ បានដឹងថា ទ្រព្យសម្បត្តិទាំងនោះជាផលចំណូលនៃបទល្មើស ។

(ii) ការចូលរួមក្នុង ការសេពគប់ជាមួយ ឬ ការសមគំនិតដើម្បីប្រព្រឹត្ត ប៉ុនប៉ងប្រព្រឹត្ត និងជួយជ្រោមជ្រែង លើកទឹកចិត្ត ជួយសម្របសម្រួល និងផ្តល់យោបល់ដល់ការប្រព្រឹត្តបទល្មើសទាំងឡាយណាដែលបានចែងអនុលោមតាមមាត្រានេះ ។

## មាត្រា ៨

## ការចាត់ទុកអំពើពុករលួយជាអំពើល្មើសច្បាប់ព្រហ្មទណ្ឌ

**១**.ទាក់ទងទៅនឹងបណ្តាបទល្មើសទាំងឡាយដូចមានចែងនៅក្នុងមាត្រា៣នៃអនុសញ្ញានេះ ភាគីនីមួយៗត្រូវអនុម័តច្បាប់ និង បណ្តាវិធានការចាំបាច់ផ្សេងទៀត ដើម្បីចាត់ទុកជាអំពើល្មើសច្បាប់ព្រហ្មទណ្ឌ កាលបើបទល្មើសទាំងនេះ ត្រូវបានប្រព្រឹត្តឡើងដោយចេតនា :

**ក**- ការសន្យា ការផ្តល់ជូន ឬ ការឱ្យទៅមន្ត្រីសាធារណៈ ដោយផ្ទាល់ក្តី ឬ ដោយប្រយោលក្តី នូវផលប្រយោជន៍មិនត្រឹមត្រូវ សម្រាប់ឱ្យមន្ត្រីរូបនោះ ឬ បុគ្គលម្នាក់ទៀត ឬ អង្គភាព ក្នុងគោលបំណងឱ្យមន្ត្រីរូបនោះបំពេញ ឬ មិនបំពេញករណីយកិច្ចជាផ្លូវការរបស់ខ្លួន ។

**ខ**- ការទទូចសុំ ឬ ការទទួលយកដោយផ្ទាល់ ឬ ដោយប្រយោលក្តី នូវផលប្រយោជន៍មិនត្រឹមត្រូវ ដោយមន្ត្រីសាធារណៈសំរាប់យកមកធ្វើជារបស់ផ្ទាល់ខ្លួន ឬ សម្រាប់បុគ្គលម្នាក់ផ្សេងទៀត ឬ សម្រាប់អង្គភាព ក្នុងគោលបំណងឱ្យមន្ត្រីរូបនោះបំពេញ ឬ មិនបំពេញករណីយកិច្ចជាផ្លូវការរបស់ខ្លួន ។

**២**-ភាគីនីមួយៗក៏ត្រូវធ្វើការពិចារណា ដើម្បីចាត់ទុកជាអំពើល្មើសច្បាប់ព្រហ្មទណ្ឌ នូវទម្រង់ផ្សេងទៀតនៃអំពើពុករលួយ ។

**៣**-ភាគីនីមួយៗក៏ត្រូវអនុម័តបណ្តាវិធានការចំាបាច់នានាដើម្បីចាត់ទុកជាអំពើល្មើសច្បាប់ព្រហ្មទណ្ឌការចូលរួមក្នុងនាមជាជនសមគំនិតនៅក្នុងបទល្មើសដូចបានកំណត់អនុលោមតាមមាត្រានេះ ។

## មាត្រា ៩

## ការចាត់ទុកអំពើធ្វើឱ្យរាំងស្ទះដល់ដំណើរការយុត្តិធម៌ជាអំពើល្មើសច្បាប់

ទាក់ទងទៅនឹងបណ្តាបទល្មើសដូចមានចែងនៅក្នុងមាត្រា ៣ នៃអនុសញ្ញានេះ ភាគីនីមួយៗត្រូវអនុម័តបណ្តាវិធានការច្បាប់ និង បណ្តាវិធានការចាំបាច់ផ្សេងទៀតដើម្បីចាត់ទុកជាអំពើល្មើសច្បាប់ព្រហ្មទណ្ឌ កាលបើ

បទល្មើសទាំងនេះត្រូវបានប្រព្រឹត្តឡើងដោយចេតនា :

**ក**- ការប្រើកំលាំងកាយ ការគំរាមកំហែង ឬ ការបំភិតបំភ័យ ឬ ការសន្យា ការផ្តល់ ឬ ការឱ្យផលប្រយោជន៍មិនត្រឹមត្រូវដើម្បីបញ្ចុះបញ្ចូលឱ្យផ្តល់សក្ខីកម្មក្លែងក្លាយ ឬ ដើម្បីជ្រៀតជ្រែកទៅក្នុងការផ្តល់សក្ខីកម្ម ឬ ការបង្ហាញភស្តុតាងនៅក្នុងនីតិវិធីរឿងក្តី ដែលទាក់ទងនឹងការប្រព្រឹត្តបទល្មើសទាំងឡាយដែលមានចែងនៅក្នុងអនុសញ្ញានេះ ។

**ខ**- ការប្រើកំលាំងកាយ ការគំរាមកំហែង ឬការបំភិតបំភ័យ ដើម្បីជ្រៀតជ្រែកក្នុងការបំពេញករណីយកិច្ចផ្លូវការដោយចៅក្រម ឬ ដោយមន្ត្រីអនុវត្តច្បាប់ ទាក់ទងនឹងការប្រព្រឹត្តបទល្មើសទាំងឡាយដែលដូចមានចែងនៅក្នុងអនុសញ្ញានេះ ។ នៅក្នុងកថាខ័ណ្ឌនេះពុំបានចែងអ្វីដែលធ្វើឱ្យប៉ះពាល់ដល់សិទ្ធិរបស់ភាគីទាំងអស់ ដែលត្រូវមានច្បាប់សំរាប់ការពារដល់ប្រភេទផ្សេងទៀតនៃមន្ត្រីសាធារណៈឡើយ ។

## មាត្រា ១០

## យុត្តាធិការ

**១**-ភាគីនីមួយៗត្រូវអនុម័តបណ្តាវិធានការចាំបាច់នានា ដើម្បីបង្កើតយុត្តាធិការរបស់ខ្លួនលើបទល្មើសទាំងឡាយដូចមានចែងអនុលោមតាមមាត្រា៥ មាត្រា៦ មាត្រា៧ មាត្រា៨និង មាត្រា៩ នៃអនុសញ្ញានេះ នៅពេលដែល :

ក-បទល្មើសកើតឡើងនៅក្នុងដែនដីរបស់ភាគីនោះ ឬ

ខ-បទល្មើសកើតឡើងនៅលើនាវា ដែលមានលើកទង់ជាតិរបស់ភាគីនោះ ឬ នៅលើយន្តហោះ ដែលចុះបញ្ជីក្រោមច្បាប់របស់ភាគីនោះ នៅចំពេលដែលបទល្មើសនោះបានកើតឡើង ។

**២**-អនុលោមតាមមាត្រា ៤នៃអនុសញ្ញានេះ ភាគីមួយក៏អាចបង្កើតយុត្តាធិការរបស់ខ្លួនលើបទល្មើសដូចតទៅនេះនៅពេលដែល :

**ក**-បទល្មើសត្រូវបានប្រព្រឹត្តឡើងប្រឆាំងនឹងពលរដ្ឋរបស់ភាគីនោះ

**ខ**-បទល្មើសត្រូវបានប្រព្រឹត្តឡើងដោយពលរដ្ឋរបស់ភាគីនោះ ឬ ប្រព្រឹត្តឡើងដោយបុគ្គលដែលគ្មានសញ្ជាតិ តែជាអ្នកមាននិវេសនដ្ឋានជាទម្លាប់នៅក្នុងដែនដីរបស់ភាគីនោះ ឬ

**គ**-បទល្មើសនោះជា :

**(i)** បទល្មើសមួយនៅក្នុងចំណោមបទល្មើសដែលបានកំណត់អនុលោមតាមមាត្រា ៦ កថាខ័ណ្ឌ១នៃអនុសញ្ញានេះ និង ត្រូវបានប្រព្រឹត្តឡើងនៅក្រៅដែនដីរបស់ខ្លួន តែក្នុងគោលបំណងប្រព្រឹត្តបទ

ល្មើសធ្ងន់ធ្ងរនៅក្នុងដែនដីរបស់ខ្លួន ។

(ii) បទល្មើសមួយនៅក្នុងចំណោមបទល្មើសដែលបានកំណត់អនុលោមតាមមាត្រា ៧ កថាខ័ណ្ឌ១ (ខ) (ii) នៃអនុសញ្ញានេះ និងត្រូវបានប្រព្រឹត្តឡើងនៅក្រៅដែនដីរបស់ខ្លួន ក្នុងគោលបំណងប្រព្រឹត្តបទល្មើសដែលបានកំណត់អនុលោមតាមមាត្រា៧ កថាខ័ណ្ឌ(ក)(i) ឬ (ii) ឬ (ខ)(i) នៃអនុសញ្ញានេះនៅក្នុងដែនដីរបស់ខ្លួន ។

៣-មាត្រា ១៩ នៃអនុសញ្ញានេះមានគោលបំណងឱ្យភាគីនីមួយៗត្រូវអនុម័តនូវបណ្តាវិធានការចាំបាច់នានាដើម្បីបង្កើតយុត្តាធិការរបស់ខ្លួនលើបទល្មើសទាំងឡាយដូចមានចែងនៅក្នុងអនុសញ្ញានេះ កាលបើជនល្មើសដែលគេសង្ស័យថាប្រព្រឹត្តបទល្មើសមានវត្តមាននៅក្នុងដែនដីរបស់ខ្លួន ហើយខ្លួនមិនធ្វើត្យាប័នបុគ្គលរូបនោះដោយសំអាងលើហេតុផលតែមួយគត់ថា បុគ្គលរូបនោះជាពលរដ្ឋរបស់ខ្លួនមួយរូបដែរ ។

៤-ភាគីនីមួយៗក៏អាចអនុម័តនូវបណ្តាវិធានការចាំច់នានាដើម្បីបង្កើតយុត្តាធិការរបស់ខ្លួនលើបទល្មើសទាំងឡាយដូចមានចែងនៅក្នុងអនុសញ្ញានេះ កាលបើជនល្មើសដែលគេសង្ស័យថាបានប្រព្រឹត្តបទល្មើសមានវត្តមាននៅក្នុងដែនដីរបស់ខ្លួន ហើយខ្លួនមិនធ្វើត្យាប័នបុគ្គលរូបនោះ ។

៥-ប្រសិនបើភាគីមួយប្រើប្រាស់យុត្តាធិការរបស់ខ្លួននៅក្រោមកថាខ័ណ្ឌ ១ ឬ២ នៃមាត្រានេះត្រូវបានគេជូនដំណឹងមក ឬម្យ៉ាងវិញទៀតបានដឹងថា មានភាគីមួយ ឬភាគី ច្រើនផ្សេងទៀតកំពុងដំណើរការស៊ើបអង្កេត ផ្តន្ទាទោស ឬ ដំណើរការនីតិវិធីនៅតុលាការទាក់ទងនឹងអំពើប្រព្រឹត្តតែមួយ នោះអាជ្ញាធរមានសមត្ថកិច្ចទាំងឡាយនៃភាគីទាំងនោះ ត្រូវធ្វើការពិគ្រោះយោបល់រវាងគ្នា និងគ្នាដើម្បីសម្របសម្រួលចំណាត់ការរបស់ខ្លួនឱ្យបានសមស្រប ។

៦-ដោយពុំមានផលប៉ះពាល់ដល់បទដ្ឋាននៃច្បាប់អន្តរជាតិជាទូទៅ អនុសញ្ញានេះពុំបានបដិសេធនីនូវការប្រើប្រាស់យុត្តាធិការព្រហ្មទណ្ឌណាមួយ ដែលបង្កើតឡើងដោយភាគីមួយអនុលោមតាមច្បាប់ប្រទេសរបស់ខ្លួននោះឡើយ ។

## ជំពូក III

## មាត្រា ១១

## ការបង្ការ -ទប់ស្កាត់អំពើជួញដូរមនុស្ស

១-ភាគីទាំងអស់ត្រូវបង្កើតនូវបណ្តាគោលនយោបាយ កម្មវិធី និង បណ្តាវិធានការផ្សេងទៀតឱ្យបានគ្រប់ជ្រុង

ជ្រោយៈ

**ក**-ដើម្បីបង្ការ-ទប់ស្កាត់ និងប្រយុទ្ធប្រឆាំងនឹងអំពើជួញដូរមនុស្ស និង

**ខ**-ដើម្បីការពារជនរងគ្រោះដោយអំពើជួញដូរមនុស្ស ជាពិសេសស្ត្រី និងកុមារកុំឱ្យទទួលរងគ្រោះសារជាថ្មីទៀត ។

**២**-ភាគីទាំងអស់ត្រូវខំប្រឹងខ្នះខ្នែងអនុវត្តបណ្តាវិធានការនានា ដូចជាធ្វើការស្រាវជ្រាវ ធ្វើយុទ្ធនាការព័ត៌មាន និងការផ្សព្វផ្សាយព័ត៌មានតាមប្រព័ន្ធឃោសនានានា និង អនុវត្តគំនិតផ្តួចផ្តើមផ្នែកសេដ្ឋកិច្ចសង្គម សំដៅបង្ការ-ទប់ស្កាត់ និង ប្រយុទ្ធប្រឆាំងនឹងអំពើជួញដូរមនុស្ស ។

**៣**-បង្កើតនូវបណ្តាគោលនយោបាយ កម្មវិធី និង បណ្តាវិធានការផ្សេងទៀតឱ្យបានសមស្រប អនុលោមតាមមាត្រានេះ ក្នុងនោះរួមមានកិច្ចសហប្រតិបត្តិការជាមួយបណ្តាអង្គការក្រៅរដ្ឋាភិបាល បណ្តាអង្គការពាក់ព័ន្ធផ្សេងទៀត និង បណ្តាផ្នែកសង្គមស៊ីវិល ។

**៤**-ភាគីទាំងអស់ត្រូវចាត់ ឬ ពង្រឹងបណ្តាវិធានការនានា ក្នុងនោះរួមទាំងតាមរយៈកិច្ចសហប្រតិបត្តិការទ្វេភាគី ឬពហុភាគី សំដៅកាត់បន្ថយកត្តាទាំងឡាយដែលធ្វើឱ្យមនុស្ស ជាពិសេសស្ត្រី និងកុមារងាយនឹងរងគ្រោះដោយអំពើជួញដូរ ដូចជា ភាពក្រីក្រ ភាពមិនសូវមានការអភិវឌ្ឍន៍ និងកង្វះខាតឱកាសស្មើគ្នា ។

**៥**-ភាគីទាំងអស់ត្រូវអនុម័ត ឬ ពង្រឹងបណ្តាវិធានការច្បាប់ ឬ បណ្តាវិធានការផ្សេងទៀត ដូចជា វិធានការអប់រំ វិធានការសង្គម ឬ វប្បធម៌ រួមទាំងតាមរយៈកិច្ចសហប្រតិបត្តិការទ្វេភាគី ឬ ពហុភាគី សំដៅទប់ស្កាត់តម្រូវការដែលផ្តត់ផ្គង់ដល់រាល់ទម្រង់នៃការធ្វើអាជីវកម្មលើមនុស្ស ជាហេតុនាំឱ្យកើតមានអំពើជួញដូរមនុស្ស ជាពិសេស ស្ត្រី និង កុមារ ។

## មាត្រា ១២

## បណ្តាផ្នែកដែលត្រូវធ្វើសហប្រតិបត្តិការ

អនុលោមតាមច្បាប់ប្រទេសរបស់ភាគីនីមួយៗ ផ្នែកដែលត្រូវធ្វើសហប្រតិបត្តិការដើម្បីបង្ការ-ទប់ស្កាត់អំពើជួញដូរមនុស្សនៅក្រោមអនុសញ្ញានេះ អាចរួមមានបណ្តាវិធានការសមស្របនានានៅក្នុងចំណោមវិធានការដទៃទៀតដូចតទៅ :

**ក**-ទប់ស្កាត់តម្រូវការដែលផ្តត់ផ្គង់រាល់ទម្រង់នៃការធ្វើអាជីវកម្មលើមនុស្ស ដែលជាហេតុនាំឱ្យកើតមានអំពើជួញ

ជួញដូរមនុស្ស ជាពិសេស ស្ត្រី និងកុមារ ។

**ខ**-ចាត់ ឬ ពង្រឹងវិធានការសមស្របនានា ដូចជាតាមរយៈកិច្ចសហប្រតិបត្តិការទ្វេភាគី ពហុភាគី ឬ តំបន់ ដើម្បីបង្ការ-ទប់ស្កាត់ និង ប្រយុទ្ធប្រឆាំងនឹងអំពើជួញដូរមនុស្ស សំដៅកាត់បន្ថយកត្តាទាំងឡាយដែលធ្វើឱ្យមនុស្សជាពិសេសស្ត្រី និង កុមារងាយរងគ្រោះដោយអំពើជួញដូរ ដូចជា ភាពក្រីក្រ ភាពមិនសូវមានការអភិវឌ្ឍន៍ កង្វះខាតការអប់រំ និងកង្វះខាតឱកាសស្មើគ្នា ។

**គ**-ពង្រឹងបណ្តាគោលនយោបាយ និង កម្មវិធីនានា ដើម្បីបង្ការ-ទប់ស្កាត់អំពើជួញដូរមនុស្ស តាមរយៈយុទ្ធនាការការស្រាវ ជ្រាវព័ត៌មាន និងការអប់រំ និងលើកកំពស់ការយល់ដឹង គំនិតផ្តួចផ្តើមផ្នែកសេដ្ឋកិច្ច និងសង្គម និងកម្មវិធីបណ្តុះបណ្តាល ជាពិសេសសំរាប់បុគ្គលដែលងាយរងគ្រោះដោយអំពើជួញដូរ ។

**ឃ**-ពង្រឹងបន្ថែមកិច្ចសហបតិបត្តិការតំបន់ក្នុងការស៊ើបអង្កេត និង ផ្តន្ទាទោសបណ្តាករណីរឿងជួញដូរមនុស្ស ។

**ង**-បង្កលទ្ធភាពឱ្យមានចលនាមនុស្សបំលាស់ទីដោយសេរី និងប្រព្រឹត្តទៅដោយស្របច្បាប់ និងត្រូវធានាប្រកាន់ខ្ជាប់នូវតម្រូវការផ្នែកអន្តោប្រវេសន៍ តាមរយៈការផ្សព្វផ្សាយព័ត៌មានជាក់លាក់ ត្រឹមត្រូវអំពីតម្រូវការ និង លក្ខខ័ណ្ឌនានា ដែលបង្កលក្ខណៈឱ្យចូលទៅ និង ចេញមកវិញ ព្រមទាំងស្នាក់នៅលើដែនដីរបស់ពួកគេរៀងៗខ្លួនដោយស្របច្បាប់ ។

**ច**-ផ្លាស់ប្តូរ និង ចែករំលែកព័ត៌មាន ស្តីពី បណ្តាវិធានការដើម្បីកាត់បន្ថយភាពងាយរងគ្រោះដោយអំពើជួញដូរមនុស្សរបស់កុមារក្នុងគោលបំណងឱ្យពួកគេអាចធំដឹងក្តីឡើង និងរស់នៅក្នុងបរិស្ថានមួយប្រកបដោយសុវត្ថិភាព ។

**ឆ**-ជម្រុញការកសាងសមត្ថភាព ក្នុងនោះរួមមាន ការបណ្តុះបណ្តាល កិច្ចសហប្រតិបត្តិការផ្នែកបច្ចេកទេស និងការរៀបចំកិច្ចប្រជុំដើម្បីសម្របសម្រួលថ្នាក់តំបន់ ។

**ជ**-ត្រូវធានានាំខ្លួនមកកាត់ទោស បុគ្គលទាំងឡាយណាដែលប្រព្រឹត្ត ឬ គាំទ្រដល់អំពើជួញដូរមនុស្ស ។

## មាត្រា ១៣

## កិច្ចសហប្រតិបត្តិការឆ្លងដែន ការត្រួតពិនិត្យ និងសុពលភាពនៃឯកសារ

**១**-ភាគីទាំងអស់ត្រូវខិតខំខ្នះខ្នែងធ្វើសហប្រតិបត្តិការឆ្លងដែនឱ្យបានសមស្របនៅក្នុងចំណោមបណ្តាទីភ្នាក់ងារត្រួតពិនិត្យព្រំដែន សំដៅបង្ការ-ទប់ស្កាត់ និង រកឱ្យឃើញអំពើជួញដូរមនុស្ស ជាអាទិ៍ តាមរយៈ:

**ក**-ការបង្កើត និង ថែរក្សាប្រព័ន្ធទំនាក់ទំនងដោយផ្ទាល់

**ខ**-បង្កើនការផ្លាស់ប្តូរ និង ចែករំលែកព័ត៌មានសំងាត់ និង ព័ត៌មានចំហ រួមមានតាមរយៈការបង្កើត

ការកសាង ឬ ការប្រើប្រាស់ទិន្នដ្ឋានសមស្រប

២-ភាគីទាំងអស់ត្រូវបង្ការ-ទប់ស្កាត់ចលនាបំលាស់ទីរបស់ពួកជួញដូរ និង ជនរងគ្រោះដោយអំពើជួញដូរមនុស្ស តាមរយៈការត្រួតពិនិត្យព្រំដែន និង ការត្រួតពិនិត្យលើការចេញឯកសារសំគាល់ខ្លួន និងឯកសារធ្វើដំណើរប្រកបដោយប្រសិទ្ធិភាព និង តាមរយៈបណ្ដាវិធានការដ៏មានប្រសិទ្ធិភាព ដើម្បីបង្ការ-ទប់ស្កាត់ការក្លែងក្លាយ ការក្លែងបន្លំ ឬ ការប្រើប្រាស់ឯកសារសំគាល់ខ្លួន និង ឯកសារធ្វើដំណើរក្លែងបន្លំ ។

## ជំពូក IV

## កិច្ចការពារ

### មាត្រា ១៤

### កិច្ចការពារជនរងគ្រោះដោយអំពើជួញដូរមនុស្ស

១-ភាគីនីមួយៗត្រូវបង្កើតគោលការណ៍ណែនាំ ឬ នីតិវិធីជាតិសំរាប់កំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរឱ្យបានត្រឹមត្រូវ ហើយបើអាចធ្វើទៅបានអាចសហការជាមួយអង្គការក្រៅរដ្ឋាភិបាលដែលផ្ដល់ជំនួយដល់ជនរងរងគ្រោះដែលពាក់ព័ន្ធ ។

២-ក្នុងករណីដែលអំពើជួញដូរកើតឡើងនៅក្នុងប្រទេសចាប់ពីពីរឡើងទៅ នោះភាគីនីមួយៗត្រូវគោរព និងទទួលស្គាល់អត្តសញ្ញាណរបស់ជនរងគ្រោះដោយអំពើជួញដូរមនុស្ស ដែលកំណត់ដោយអាជ្ញាធរមានសមត្ថកិច្ចនៃភាគីដែលទទួល ។

៣-ការកំណត់អត្តសញ្ញាណរបៀបនេះត្រូវជូនដំណឹងឱ្យរដ្ឋបញ្ជូនបានជ្រាប ដោយភាគីទទួលមិនត្រូវធ្វើការពន្យាពេលដោយមិនសមហេតុផលនោះឡើយ លើកលែងតែជនរងគ្រោះផ្ដល់ព័ត៌មានផ្សេងពីនេះ ។

៤-ភាគីនីមួយៗត្រូវពិចារណាអនុម័តនូវបណ្ដាវិធានការច្បាប់ និង បណ្ដាវិធានការសមស្របផ្សេងទៀត ដែលអនុញ្ញាតឱ្យជនរងគ្រោះដោយអំពើជួញដូរមនុស្សបន្តនៅក្នុងដែនដីរបស់ខ្លួនជាបណ្ដោះអាសន្ន ឬជាអចិន្ត្រៃយ៍ក្នុងបណ្ដាករណីដែលមានលក្ខណៈសមស្រប ។ ភាគីនីមួយៗត្រូវធ្វើការពិចារណាឱ្យបានត្រឹមត្រូវអំពីកត្តាមនុស្សធម៌ និងសេចក្ដីមេត្តាករុណាចំពោះបញ្ហានេះ ។

៥-ភាគីនីមួយៗត្រូវខំប្រឹងខ្នះខ្នែងផ្ដល់សុវត្ថិភាពផ្លូវកាយដល់ជនរងគ្រោះដោយអំពើជួញដូរមនុស្សក្នុងអំឡុងពេលដែលពួកគេស្នាក់នៅក្នុងដែនដីរបស់ខ្លួន ។

៦-ក្នុងបណ្ដាករណីសមស្រប និង ស្ថិតក្រោមវិសាលភាពនៃច្បាប់ក្នុងប្រទេសរបស់ខ្លួនអាចអនុវត្តបាន ភាគី

នីមួយៗត្រូវការពារសិទ្ធិនៃជីវភាពឯកជន និង អត្តសញ្ញាណរបស់ជនរងគ្រោះដោយអំពើជួញដូរមនុស្ស រួមមាន ជាអាទិ៍ ការដំណើរការរឿងក្តីតាមផ្លូវច្បាប់ដែលទាក់ទងនឹងអំពើជួញដូរត្រូវរក្សាទុកជាការសំងាត់។

**៧**-ដោយអនុលោមតាមច្បាប់ បទបញ្ញត្តិ បទបញ្ជា និង គោលនយោបាយនានារបស់ប្រទេសខ្លួន និងក្នុងករណីសមស្របនានា ភាគីនីមួយៗត្រូវពិចារណាមិនដាក់ឱ្យជនរងគ្រោះដោយអំពើជួញដូរមនុស្សទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌ ឬ ផ្នែករដ្ឋបាលនូវអំពើខុសច្បាប់ទាំងឡាយដែលពួកគេបានប្រព្រឹត្ត ប្រសិនបើអំពើទាំងនោះមានទាក់ទងដោយផ្ទាល់ទៅនឹងអំពើជួញដូរ។

**៨**-ភាគីនីមួយៗមិនត្រូវឃុំខ្លួន ឬ ដាក់ពន្ធនាគារ នូវបុគ្គលទាំងឡាយដែលត្រូវបានអាជ្ញាធរមានសមត្ថកិច្ចរបស់ខ្លួនបានកំណត់អត្តសញ្ញាណថាជាជនរងគ្រោះដោយអំពើជួញដូរមនុស្ស ទាំងនៅមុនពេល ក្នុងអំឡុងពេល និងក្រោយពេលចំណាត់ការរឿងក្តីរដ្ឋប្បវេណី ព្រហ្មទណ្ឌ ឬ រដ្ឋបាលចំពោះអំពើជួញដូរមនុស្ស។

**៩**-ភាគីនីមួយៗត្រូវជូនដំណឹងតាមពេលវេលាសមស្រប ឱ្យជនរងគ្រោះដោយអំពើជួញដូរមនុស្សដែលគេបានកំណត់អត្តសញ្ញាណរួចជ្រាបនូវព័ត៌មាន ស្តីអំពីប្រភេទនៃកិច្ចការពារ ជំនួយ និងការគាំទ្រដែលពួកគេមានសិទ្ធិទទួលបានដោយអនុលោមតាមច្បាប់ជាតិ និង អនុសញ្ញានេះ។

**១០**-ភាគីនីមួយៗ ប្រសិនបើអាចធ្វើទៅបាន ត្រូវផ្តល់ការថែរក្សា និង គាំទ្រដល់ជនរងគ្រោះដោយអំពើជួញដូរមនុស្ស ក្នុងនោះក្នុងករណីសមស្របត្រូវរួមសហប្រតិបត្តិកាជាមួយបណ្តាអង្គការក្រៅរដ្ឋាភិបាលដែលពាក់ព័ន្ធ និងបណ្តាអង្គការសង្គមស៊ីវិលផ្សេងទៀត ក្នុងការងារដូចខាងក្រោមៈ

**ក**-ការផ្តល់កន្លែងស្នាក់នៅសមស្រប

**ខ**-ការប្រឹក្សាយោបល់ និង ព័ត៌មាន ជាពិសេសទាក់ទងនឹងសិទ្ធិតាមផ្លូវច្បាប់របស់ពួកគេ តាមភាសាដែលជនរងគ្រោះដោយអំពើជួញដូរមនុស្សអាចយល់បាន។

**គ**-ជំនួយវេជ្ជសាស្ត្រ ចិត្តសាស្ត្រ និង សំភារៈ និង

**ឃ**-កាលានុវត្តភាពការងារ សិក្សាអប់រំ និង បណ្តុះបណ្តាល។

**១១**-ភាគីនីមួយៗត្រូវធ្វើកិច្ចខិតខំឱ្យអស់លទ្ធភាព ដើម្បីជួយក្នុងការធ្វើសមាហរណកម្មជនរងគ្រោះដោយអំពើជួញដូរមនុស្សចូលទៅក្នុងសង្គមនៃភាគីដែលបញ្ជូនវិញ។

**១២**-ភាគីនីមួយៗ ក្នុងការអនុវត្តបទបញ្ញត្តិទាំងឡាយនៃមាត្រានេះ ត្រូវធ្វើការពិចារណាដល់អាយុ ភេទ និងតម្រូវការពិសេសរបស់ជនរងគ្រោះដោយអំពើជួញដូរមនុស្ស ជាពិសេសតម្រូវការពិសេសរបស់កុមារ។

*បកប្រែក្រៅផ្លូវការដោយ លោក ឧត្តមសេនីយ៍ត្រី សុខ រស្មី*

១៣-ភាគីនីមួយៗត្រូវធានាថា ប្រព័ន្ធច្បាប់ក្នុងប្រទេសរបស់ខ្លួនរួមមានបណ្ដាវិធានការដែលផ្ដល់ជូនជនរងគ្រោះដោយអំពើជួញដូរមនុស្សនូវលទ្ធភាពទទួលបានសំណងជម្ងឺចិត្តសំរាប់ជួសជុលការខូចខាតដែលពួកគេបានទទួលរង ។

១៤-រដ្ឋជាភាគីនីមួយៗត្រូវចាត់ចែងទុកដោយឡែកមូលនិធិសមស្រប បើអាចធ្វើទៅបាន ត្រូវបង្កើតមូលនិធិជាតិសំរាប់អាណត្តិព្យាបាលភាពទុកសំរាប់ការថែរក្សា និង គាំទ្រជនរងគ្រោះដោយអំពើជួញដូរមនុស្ស ។

## មាត្រា ១៥
## ការធ្វើមាតុភូមិនិវត្តន៍ និងការបញ្ជូនជនរងគ្រោះត្រឡប់វិញ

១-ភាគីដែលជនរងគ្រោះដោយអំពើជួញដូរមនុស្សត្រូវជាពលរដ្ឋរបស់ខ្លួន ឬ ដែលជនរងគ្រោះនោះមានសិទ្ធិស្នាក់នៅជាអចិន្ត្រៃយ៍នៅពេលដែលបានចូលទៅក្នុងដែនដីនៃរដ្ឋជាភាគីទទួលនោះ ត្រូវធ្វើការសម្របសម្រួល និងត្រូវយល់ព្រមទៅនឹងបញ្ជូនបុគ្គលនោះត្រឡប់មកវិញ ដោយមិនត្រូវមានការពន្យាពេលដោយគ្មានមូលហេតុសមស្របឡើយ ដោយត្រូវយកចិត្តទុកដាក់ជាពិសេសដល់សុវត្ថិភាពរបស់បុគ្គលនោះ ។

២-នៅពេលដែលភាគីមួយបញ្ជូនជនរងគ្រោះត្រឡប់ស្របតាមកថាខ័ណ្ឌ ១ នៃមាត្រានេះ ការបញ្ជូនត្រឡប់នេះត្រូវយកចិត្តទុកដាក់ជាពិសេសដល់សុវត្ថិភាពរបស់បុគ្គលរងគ្រោះនោះ និង ដល់ស្ថានភាពនៃចំណាត់ការលើរឿងក្តីតាមផ្លូវច្បាប់ទាក់ទងនឹងហេតុការណ៍ដែលបុគ្គលនេះជាជនរងគ្រោះដោយអំពើជួញដូរ ។

៣-យោងតាមកថាខ័ណ្ឌ ១ និង(២) នៃមាត្រានេះ ដោយតបតាមសំណើរបស់ភាគីទទួល ភាគីដែលគេស្នើសុំមិនត្រូវធ្វើការពន្យាពេលដោយគ្មានមូលហេតុសមស្របឡើយ គឺត្រូវធ្វើការផ្ទៀងផ្ទាត់ដើម្បីបញ្ជាក់ថា បុគ្គលនោះពិតជាពលរដ្ឋរបស់ខ្លួន ឬ ជាអ្នកស្នាក់នៅអចិន្ត្រៃយ៍នៅពេលដែលបានចូលទៅក្នុងដែនដីនៃភាគីទទួលនោះ ។

៤-ដើម្បីសម្របសម្រួលដល់ការបញ្ជូនត្រឡប់ជនរងគ្រោះដោយអំពើជួញដូរមនុស្ស ដែលគ្មានឯកសារត្រឹមត្រូវភាគីដែលបុគ្គលរងគ្រោះជាពលរដ្ឋរបស់ខ្លួន ឬ ដែលជនរងគ្រោះមានសិទ្ធិស្នាក់នៅអចិន្ត្រៃយ៍នៅពេលដែលបានចូលទៅក្នុងដែនដីនៃភាគីទទួល តបតាមសំណើរបស់ភាគីទទួល ត្រូវយល់ព្រមចេញឯកសារធ្វើដំណើរ ឬ លិខិតអនុអនុញ្ញាតផ្សេងៗដែលអាចជាការចាំបាច់ដើម្បីផ្តល់លទ្ធភាពឱ្យបុគ្គលនោះធ្វើដំណើរទៅកាន់ និង ត្រឡប់ចូលមកក្នុងទឹកដីរបស់ខ្លួនវិញបាន ។

៥-ភាគីនីមួយៗត្រូវអនុម័តនូវបណ្ដាវិធានការច្បាប់ និង បណ្ដាវិធានការចាំបាច់ផ្សេងទៀតដែលសមស្របដើម្បីបង្កើតនូវកម្មវិធីធ្វើមាតុភូមិនិវត្តន៍ ហើយប្រសិនបើចាំបាច់ ត្រូវមានការចូលរួមពីបណ្ដាស្ថាប័នជាតិ ឬ អន្តរជាតិ

និង បណ្ដាអង្គការក្រៅរដ្ឋាភិបាលដែលពាក់ព័ន្ធ ។

**៦**-មាត្រានេះនឹងមិនបង្កឱ្យមានផលប៉ះពាល់ដល់សិទ្ធិទាំងឡាយ ដែលជនរងគ្រោះដោយអំពើជួញដូរមនុស្សត្រូវទទួលបានតាមច្បាប់ប្រទេសរបស់ភាគីដែលទទួល ។

**៧**-មាត្រានេះនឹងមិនបង្កឱ្យមានផលប៉ះពាល់ដល់បណ្ដាបទបញ្ញត្តិ ស្ដីពី កិច្ចព្រមព្រៀងទ្វេភាគី និង ពហុភាគីដែលអាចអនុវត្តបាន ឬ បណ្ដាកិច្ចព្រមព្រៀងផ្នែកអន្តោប្រវេសន៍ ដែលមានចែងអំពីសិទ្ធិ និង ឯកសិទ្ធិដែលមានលក្ខណៈអនុគ្រោះច្រើនជាងសម្រាប់ជនរងគ្រោះដោយអំពើជួញដូរមនុស្ស ។

## ជំពូក V

## ការអនុវត្តច្បាប់

### មាត្រា ១៦

### ការអនុវត្តច្បាប់ និង ការផ្ដន្ទាទោស

**១**-ភាគីនីមួយៗត្រូវអនុម័តណ្ដាវិធានការចាំបាច់នានាដើម្បីធានាថា អាជ្ញាធរមានសមត្ថកិច្ចទាំងអស់ ដែលទទួលបន្ទុកដោះស្រាយរឿងក្ដីជួញដូរមនុស្សត្រូវបានបំពាក់នូវជំនាញ ឬ ចំណេះដឹងសមស្របក្នុងការប្រយុទ្ធប្រឆាំងនឹងអំពើជួញដូរមនុស្ស និង ការពារជនរងគ្រោះ ហើយយកល្អត្រូវជ្រើសតាំងអង្គភាព ឬ អាជ្ញាធរឯកទេសដើម្បីបំពេញគោលបំណងនេះ ។

**២**-ភាគីនីមួយៗត្រូវចាត់បណ្ដាវិធានការឱ្យសកម្ម និង មានប្រសិទ្ធិភាពដើម្បីរកឱ្យឃើញ ទប់ស្កាត់ និងដាក់ទោសអំពើពុករលួយ ការសំអាតប្រាក់ ការចូលរួមក្នុងក្រុមឧក្រិដ្ឋជនដែលមានអង្គការចាត់តាំង និងអំពើធ្វើឱ្យរាំងស្ទះដល់ដំណើរការយុត្តិធម៌ ដែលជាបច្ច័យនាំឱ្យកើតមានអំពើជួញដូរមបុស្ស ។

**៣**-ភាគីនីមួយៗត្រូវធានាថា ប្រព័ន្ធច្បាប់របស់ខ្លួនមានប្រសិទ្ធិភាព ដើម្បីចាត់វិធានការលើរឿងក្ដីជួញដូរដូរមនុស្ស ។

**៤**-ភាគីនីមួយៗត្រូវអនុម័តរាល់វិធានការចាំបាច់នានា ដើម្បីធានាដល់ការសម្របសម្រួលគោលនយោបាយ និងសកម្មភាពរបស់បណ្ដាស្ថាប័នរដ្ឋាភិបាលខ្លួន និងបណ្ដាទីភ្នាក់ងារសាធារណៈផ្សេងទៀតដែលប្រឆាំងនឹងអំពើជួញដូរមនុស្ស បើអាចធ្វើទៅបានគឺតាមរយៈការបង្កើតឱ្យមានស្ថាប័នសម្របសម្រួល ដើម្បីប្រយុទ្ធប្រឆាំងនឹងឧក្រិដ្ឋកម្មដែលមានអង្គការចាត់តាំង ដូចជាអំពើជួញដូរមនុស្ស ការសំអាតប្រាក់ និងអំពើធ្វើឱ្យរាំងស្ទះដល់ដំណើរការ

យុត្តិធម៌។

**៥**-ដោយអនុលោមតាមច្បាប់ប្រទេសរបស់ភាគីបញ្ជូន និងភាគីទទួល តាមរយៈកិច្ចសហប្រតិបត្តិការក្រៅផ្លូវការ ឬ ជំនួយផ្នែកច្បាប់ទៅវិញទៅមក ភាគីនីមួយៗត្រូវជំរុញលើកទឹកចិត្តដល់ជនរងគ្រោះដោយអំពើជួញដូរមនុស្ស ឱ្យស្ម័គ្រចិត្តចូលទៅស្នាក់នៅជាបណ្តោះអាសន្ននៅក្នុងដែនដីរបស់ភាគីទទួល ក្នុងគោលបំណងផ្តល់សក្ខីកម្ម ឬម្យ៉ាងវិញទៀត ដើម្បីធ្វើសហប្រតិបត្តិការក្នុងការផ្តន្ទាទោសពួកជួញដូរ ស្របគ្នានឹងការយកចិត្តទុកដាក់ជាពិសេសដល់សុវត្ថិភាពរបស់ជនរងគ្រោះ។

**៦**-ភាគីនីមួយៗត្រូវផ្តល់ និងពង្រឹងកម្មវិធីបណ្តុះបណ្តាលជូនមន្ត្រីពាក់ព័ន្ធលើការបង្ការ-ទប់ស្កាត់ និងប្រយុទ្ធប្រឆាំងនឹងអំពើជួញដូរមនុស្ស ដោយត្រូវផ្តោតយកចិត្តទុកដាក់លើវិធីសាស្ត្រ ដែលត្រូវយកមកប្រើក្នុងការបង្ការ-ទប់ស្កាត់អំពើជួញដូរ ការស៊ើបអង្កេត និងការផ្តន្ទាទោសពួកជួញដូរ ព្រមទាំងការការពារសិទ្ធិរបស់ជនរងគ្រោះ រួមទាំងកិច្ចការពារជនរងគ្រោះ និងក្រុមគ្រួសាររបស់ពួកគេពីពួកជួញដូរ និងសិទ្ធិនៃជីវភាពឯកជនរបស់ជនរងគ្រោះ។

**៧**-ភាគីនីមួយៗត្រូវចាត់វាល់វិធានការចាំបាច់នានា សំដៅថែរក្សាសុចរិតភាពនៃដំណើរការយុត្តិធម៌ព្រហ្មទណ្ឌ រួមទាំងតាមរយៈការការពារជនរងគ្រោះ និងសាក្សីមិនឱ្យមានការបំភិតបំភ័យ និងការយាយី ហើយចាំបាច់ត្រូវដាក់ទោសជនប្រព្រឹត្តបទល្មើសឱ្យសមទៅនឹងអំពើដែលគេបានប្រព្រឹត្ត និងឱ្យសមស្របនឹងករណីរឿង។

**៨**-ភាគីនីមួយៗបើអាចធ្វើទៅបាន ត្រូវបង្កើតឱ្យមាននៅក្រោមច្បាប់ជាតិរបស់ខ្លួននូវអាជ្ញាយុកាលដែលមានរយៈពេលវែង ដែលក្នុងនោះត្រូវចាប់ផ្តើមដំណើរការរឿងក្តីចំពោះបទល្មើសទាំងឡាយដែលមានចែងនៅក្នុងអនុសញ្ញានេះ និងត្រូវមានអាជ្ញាយុកាលវែងជាងនេះទៀតចំពោះជនជាប់សង្ស័យថាបានប្រព្រឹត្តបទល្មើស ហើយបានគេចវេសពីការកាត់ទោស។

**៩**-អនុសញ្ញានេះពុំមានចែងនូវអ្វីនាំឱ្យប៉ះពាល់ដល់គោលការណ៍ ដែលពិពណ៌នាអំពីបទល្មើសដែលមានចែងស្របតាមតាមអនុសញ្ញានេះ និងការការពារតាមផ្លូវច្បាប់ដែលអាចអនុវត្តបាន ឬ បណ្តាគោលការណ៍ច្បាប់ផ្សេងទៀតដែលគ្រប់គងលើភាពស្របច្បាប់នៃអំពើប្រព្រឹត្ត ដែលត្រូវបានទុកដោយឡែកសំរាប់ច្បាប់ជាតិរបស់រដ្ឋជាភាគី ហើយដែលបទល្មើសទាំងនេះនឹងត្រូវផ្តន្ទាទោស និងដាក់ទោសអនុលោមតាមច្បាប់នោះ។

## មាត្រា ១៧

## ការរឹបអូស និង ការដកហូត

១-អនុលោមតាមប្រព័ន្ធច្បាប់របស់ប្រទេស និងតាមលទ្ធភាពទាំងអស់ដែលខ្លួនមាន ភាគីនីមួយៗត្រូវអនុម័តនូវបណ្តាវិធានការចាំបាច់នានា ដើម្បីផ្តល់លទ្ធភាពដល់ការរឹបអូសនូវ :

**ក-** ផលចំណូលនៃបទល្មើស ដែលទទួលបានមកពីបទល្មើសនានាដូចមានចែងនៅក្នុងអនុសញ្ញានេះ ឬ ទ្រព្យសម្បត្តិដែលមានតម្លៃស្មើនឹងផលចំណូលទាំងនេះ ។

**ខ-** ទ្រព្យសម្បត្តិ សំភារៈ ឬ បណ្តាគ្រឿងឧបករណ៍ផ្សេងទៀត ដែលត្រូវបានប្រើប្រាស់ ឬ ដែលបំរុងយកទៅប្រើប្រាស់ក្នុងបទល្មើសនានា ដូចមានចែងនៅក្នុងអនុសញ្ញានេះ ។

**២**-ភាគីនីមួយៗត្រូវអនុម័តនូវបណ្តាវិធានការចាំបាច់នានាដើម្បីផ្តល់លទ្ធភាពដល់ការកំណត់អត្តសញ្ញាណ ការតាមដាន ការបង្កកទុក ឬ ដកហូតនូវរាល់សំភារៈយោងតាមកថាខ័ណ្ឌ១ នៃមាត្រានេះ ក្នុងគោលបំណងរឹបអូសជាយថាហេតុ ។

**៣**-ប្រសិនបើផលចំណូលនៃបទល្មើសត្រូវបានប្តូរធាតុដើម ឬ ផ្លាស់ប្តូរទៅជាទ្រព្យសម្បត្តិផ្សេងដោយអន្លើ ឬ ទាំងស្រុង ទ្រព្យសម្បត្តិប្រភេទនេះនឹងត្រូវប្រឈមនឹងបណ្តាវិធានកាដូចមានចែងរក្នុងមាត្រានេះ ជំនួសឱ្យផលចំណូលនោះវិញ ។

**៤**-ប្រសិនបើផលចំណូលនៃបទល្មើសត្រូវបានយកមកដាក់បញ្ចូលគ្នាជាមួយទ្រព្យសម្បត្តិ ដែលទទួលបានមកពីប្រភពស្របច្បាប់ នោះទ្រព្យសម្បត្តិប្រភេទនេះត្រូវប្រឈមទៅនឹងការរឹបអូសឱ្យស្មើទៅនឹងតម្លៃប៉ាន់ប្រមាណនៃផលចំណូលដែលត្រូវបានយកមកដាក់បញ្ចូលគ្នានោះ ដោយពុំមានផលប៉ះពាល់ដល់អំណាចដែលទាក់ទងនឹងការរឹបអូស ឬ ដកហូតឡើយ ។

**៥**-ចំណូល ឬ ផលប្រយោជន៍ផ្សេងទៀតដែលបានមកពីផលចំណូលនៃបទល្មើស បានមកពីទ្រព្យសម្បត្តិដែលកើតចេញពីការប្តូរធាតុដើម ឬ ការផ្លាស់ប្តូរចំណូលនៃបទល្មើស ឬ បានមកពីទ្រព្យសម្បត្តិដែលកើតចេញពីការដាក់បញ្ចូលគ្នាជាមួយផលចំណូលនៃបទល្មើស ក៏ត្រូវប្រឈមនឹងបណ្តាវិធានការដូចបានលើកឡើងក្នុងមាត្រានេះដូចគ្នា និងមានទំហំប៉ុនគ្នាទៅនឹងផលចំណូលនៃបទល្មើសផងដែរ ។

**៦**-មាត្រានេះ និងមាត្រា ២១ នៃអនុសញ្ញានេះមានគោលបំណងឱ្យភាគីនីមួយៗផ្តល់អំណាចឱ្យតុលាការរបស់ខ្លួន ឬ អាជ្ញាធរមានសមត្ថកិច្ចដទៃទៀតចេញបញ្ជាឱ្យផ្តល់ ឬ ដកហូតបណ្តាឯកសារធនាគារ ឯកសារហិរញ្ញវត្ថុ និង ឯកសារពាណិជ្ជកម្មនានា ។ ភាគីនីមួយៗ មិនត្រូវបដិសេធន៏ទៅនឹងការប្រតិបត្តិតាមបណ្តាបទបញ្ញត្តិដែលមានចែងនៅ

ក្នុងកថាខ័ណ្ឌនេះ ដោយសារតែសំអាងលើការរក្សាការសំងាត់របស់ធនាគារនោះឡើយ ។

**៧**-ភាគីនីមួយៗអាចពិចារណាអំពីលទ្ធភាពទាមទារឱ្យជនល្មើសបញ្ចេញឱ្យដឹងពីប្រភពស្របច្បាប់នៃផលចំណូលនៃបទល្មើសដែលជាប់មន្ទិល ឬ ទ្រព្យសម្បត្តិផ្សេងទៀតដែលប្រឈមនឹងការដកហូត ល្គឹកណាការទាមទារនេះស្របទៅនឹងបណ្តាគោលការណ៍នៃច្បាប់ជាតិរបស់ខ្លួននិងស្របនឹងចរិតនៃនីតិវិធីតុលាការ និងបណ្តានីតិវិធីផ្សេងទៀត ។

**៨**-បទបញ្ញត្តិទាំងឡាយនៃមាត្រានេះនឹងមិនត្រូវបានចាត់ទុកថា មានផលប៉ះពាល់ដល់សិទ្ធិប្រកបដោយសុចរិតភាពរបស់ភាគីទីបីឡើយ ។

**៩**-គ្មានចំណុចអ្វីនៅក្នុងមាត្រានេះនាំឱ្យប៉ះពាល់ដល់គោលការណ៍ ដែលបានកំណត់ និង អនុវតន្ទូវបណ្តាវិធានការដូចបានលើកឡើងនៅក្នុងមាត្រានេះស្របតាម និង អនុលោមតាមបណ្តាបទបញ្ញត្តិនានានៃច្បាប់ជាតិរបស់ភាគីមួយ ។

## ជំពូក VI

## កិច្ចសហប្រតិបត្តិការអន្តរជាតិ

### មាត្រា ១៨

### ជំនួយផ្នែកច្បាប់ទៅវិញទៅមកនៅក្នុងរឿងក្តីព្រហ្មទណ្ឌ

**១**-ដើម្បីប្រយុទ្ធប្រឆាំងនឹងបណ្តាបទល្មើសជួញដូរមនុស្ស ដែលមានចរិតជាបទល្មើសឆ្លងដែន ដោយអនុលោមតាមច្បាប់របស់ប្រទេសរៀងៗខ្លួន ភាគីទាំងអស់ត្រូវផ្តល់ឱ្យគ្នាទៅវិញទៅមកឱ្យអស់ពីលទ្ធភាពនូវវិធានការទាំងឡាយស្តីពី ការជំនួយផ្លូវច្បាប់ទៅវិញទៅមកនៅក្នុងការស៊ើបអង្កេតព្រហ្មទណ្ឌ ឬក្នុងនីតិវិធីរឿងក្តីព្រហ្មទណ្ឌផ្សេងទៀតទាក់ទងទៅនឹងបណ្តាបទល្មើសដែលមានចែងអនុលោមតាមមាត្រា ៥ នៃអនុសញ្ញានេះ ។

**២**-ភាគីទាំងអស់ត្រូវអនុវត្តបណ្តាកាតព្វកិច្ចរបស់ខ្លួន ដោយយោងតាមកថាខ័ណ្ឌ ១ នៃមាត្រានេះឱ្យបានស្របតាមសន្ធិសញ្ញា ស្តីពី ជំនួយផ្នែកច្បាប់ទៅវិញទៅមកនៅក្នុងរឿងក្តីព្រហ្មទណ្ឌ ។

### មាត្រា ១៩

### បត្យាប័ន

**១**-បទល្មើសនីមួយៗដូចបានកំណត់ ដោយអនុលោមតាមមាត្រា ៥ នៃអនុសញ្ញានេះត្រូវបានចាត់ទុកថាជាបទល្មើស

ដែលអាចធ្វើបត្យាប័នបាននៅក្នុងសន្ធិសញ្ញាទាំងឡាយដែលនៅជាធរមានរវាងបណ្តាភាគីទាំងអស់។ ភាគីទាំងអស់ត្រូវធានាដាក់បញ្ចូលបទល្មើសទាំងនេះឱ្យទៅជាបទល្មើសដែលអាចធ្វើបត្យាប័នបានក្នុងគ្រប់សន្ធិសញ្ញាបត្យាប័នទាំងអស់ដែលនឹងត្រូវសម្រេចរវាងពួកគេ។

២-ប្រសិនបើភាគីមួយដែលធ្វើបត្យាប័នដោយយកសន្ធិសញ្ញាជាធរមានមកធ្វើជាលក្ខខ័ណ្ឌ ទទួលបានសំណើសុំធ្វើបទ្យាប័នពីភាគីមួយទៀតដែលខ្លួនពុំមានសន្ធិសញ្ញាបត្យាប័នជាមួយ រដ្ឋនោះអាចចាត់ទុកអនុសញ្ញានេះជាមូលដ្ឋានច្បាប់សំរាប់ធ្វើបត្យាប័នដែលទាក់ទងនឹងបទល្មើសណាមួយដែលមានចែងអនុលោមតាមមាត្រា ៥ នៃអនុសញ្ញានេះ។

៣-អនុលោមតាមបណ្តាបទបញ្ញត្តិទាំងឡាយនៃច្បាប់របស់ប្រទេស និង បណ្តាសន្ធិសញ្ញាបត្យាប័នរបស់ខ្លួន និងអាស្រ័យដោយមានជំនឿថា ជាកាលៈទេសៈតម្រូវ និងបន្ទាន់បំផុត និងដើម្បីឆ្លើយតបតាមសំណើរបស់ភាគីដាក់សំណើ នោះភាគីទទួលសំណើអាចចាប់យកបុគ្គលដែលកំពុងត្រូវបានស្នើសុំឱ្យធ្វើបត្យាប័ន និងកំពុងមានវត្តមាននៅក្នុងដែនដីរបស់ខ្លួននោះមកឃុំខ្លួន ឬអាចចាត់បណ្តាវិធានការសមស្របផ្សេងទៀតដើម្បីធានាថាបុគ្គលនោះមានវត្តមាននៅពេលចំណាត់ការធ្វើបត្យាប័ន។

៤-ប្រសិនបើគេបានរកឃើញជនល្មើស ដែលគេសង្ស័យប្រព្រឹត្តបទល្មើសកំពុងស្ថិតនៅក្នុងដែនដីរបស់ភាគីមួយ ប្រសិនបើភាគីនោះមិនធ្វើបត្យាប័នបុគ្គលដែលពាក់ព័ន្ធនឹងបទល្មើសដូចមានចែងអនុលោមតាមមាត្រា ៥ នៃអនុសញ្ញានេះ ដោយសំអាងលើហេតុផលតែមួយគត់ថា បុគ្គលនោះជាពលរដ្ឋរបស់ខ្លួន តាមសំណើរបស់ភាគីដែលស្នើសុំធ្វើបត្យាប័ន នោះភាគីទទួលសំណើត្រូវមានកាតព្វកិច្ចបញ្ជូនរឿងក្តីទៅឱ្យអាជ្ញាធរមានសមត្ថកិច្ចរបស់ខ្លួនដើម្បីផ្តន្ទាទោស ដោយមិនត្រូវមានការពន្យាពេលដោយមិនសមហេតុផល។ អាជ្ញាធរមានសមត្ថកិច្ចទាំងនោះត្រូវធ្វើការសម្រេចចិត្ត និងចាត់វិធានការលើរឿងក្តីរបស់ខ្លួនឱ្យបានម៉ឺងម៉ាត់ដូចគ្នាទៅនឹងចំណាត់លើរឿងក្តីនៃបទល្មើសដែលដទៃទៀតទៅតាមច្បាប់របស់ភាគីនោះ។ ភាគីពាក់ព័ន្ធទាំងអស់ត្រូវធ្វើសហប្រតិបត្តិការគ្នា ជាពិសេសលើទិដ្ឋភាពនីតិវិធី និងភស្តុតាងដើម្បីធានាប្រសិទ្ធិភាពនៃការផ្តន្ទាទោស។

៥-មាត្រានេះមានគោលបំណងឱ្យភាគីនីមួយៗ តែងតាំងអាជ្ញាធរកណ្តាល ដើម្បីបានជ្រាបពីព័ត៌មាននៃការតម្កល់ទុកអនុសញ្ញានេះ។

## មាត្រា ២០

## កិច្ចសហប្រតិបត្តិការលើផ្នែកអនុវត្តច្បាប់

១. ដោយអនុលោមតាមប្រព័ន្ធច្បាប់ និង ប្រព័ន្ធរដ្ឋបាលរបស់ប្រទេសរៀងៗខ្លួន ភាគីទាំងអស់ត្រូវធ្វើសហប្រតិបត្តិការឱ្យបានជិតស្និតរវាងគ្នា និងគ្នាសំដៅលើកស្ទួយប្រសិទ្ធិភាពសកម្មភាពអនុវត្តច្បាប់ដើម្បីប្រយុទ្ធប្រឆាំងនឹងបណ្តាបទល្មើសដូចមានចែងនៅក្នុងអនុសញ្ញានេះ ។ជាពិសេសភាគីនីមួយៗត្រូវអនុម័តបណ្តាវិធានការប្រកបដោយប្រសិទ្ធិភាពដូចខាងក្រោម :

ក-ធ្វើឱ្យប្រសើរឡើង ហើយក្នុងករណីចាំបាច់ ត្រូវបង្កើតក៏ដូចជាប្រើប្រាស់ប្រព័ន្ធទំនាក់ទំនងដែលមានស្រាប់រវាងបណ្តាអាជ្ញាធរ ទីភ្នាក់ងារមានសមត្ថកិច្ច និង សេវាកម្មនានាដើម្បីសម្របសម្រួលការផ្លាស់ប្តូរព័ត៌មានបានរហ័ស និងប្រកបដោយសុវត្ថិភាពទាក់ទងនឹងរាល់ទិដ្ឋភាពនៃបទល្មើស ដែលមានចែងនៅក្នុងអនុសញ្ញានេះ ក្នុងនោះរួមទាំងការទំនាក់ទំនង ផ្លាស់ប្តូរព័ត៌មានអំពីបណ្តាសកម្មភាពល្មើសផ្សេងទៀតផងដែរ ប្រសិនបើរដ្ឋជាភាគីទាំងអស់យល់ឃើញថាជាការសមស្រប ។

ខ- ធ្វើសហប្រតិបត្តិការជាមួយបណ្តាភាគីផ្សេងទៀត ក្នុងការស៊ើបសួរព័ត៌មានផ្សេងៗអំពីបទល្មើសដែលមានចែងនៅក្នុងអនុសញ្ញានេះ ទាក់ទងនឹង :

(i) អត្តសញ្ញាណ ទីសំចត និងបណ្តាសកម្មភាពរបស់បុគ្គលទាំងឡាយដែលត្រូវបានសង្ស័យថាមានការពាក់ព័ន្ធនឹងបទល្មើសនានា ឬ ទីកន្លែងរបស់បុគ្គលដែលពាក់ព័ន្ធផ្សេងទៀត ។

(ii) ការបំលាស់ទីនៃផលចំណូលនៃបទល្មើស ឬទ្រព្យសម្បត្តិដែលបានមកពីការប្រព្រឹត្តបទល្មើសទាំងនេះ

(iii) ការបំលាស់ទីនៃទ្រព្យសម្បត្តិ ឬ សំភារៈ ឬគ្រឿងឱ្យបករណ៍ផ្សេងទៀតដែលបានប្រើប្រាស់ ឬមានបំណងនឹងប្រើប្រាស់ក្នុងការប្រព្រឹត្តបទល្មើស

គ-ពេលមានឱកាសសមស្រប ផ្តល់នូវវត្ថុតាង ឬ បរិមាណនៃសារធាតុក្នុងគោលបំណងយកមកធ្វើវិភាគ ឬដើម្បីបំរើដល់ការស៊ើបអង្កេត ។

ឃ-បង្កលក្ខណៈងាយស្រួលឱ្យការសម្របសម្រួលប្រព្រឹត្តទៅដោយប្រសិទ្ធិភាព រវាងបណ្តាអាជ្ញាធរមានសមត្ថកិច្ច បណ្តាទីភ្នាក់ងារ និងសេវាកម្មនានា និងលើកទឹកចិត្តឱ្យមានការផ្លាស់ប្តូរបុគ្គលិក និងអ្នកជំនាញផ្សេងៗទៅវិញទៅមក រួមទាំងការតែងតាំងមន្ត្រីទំនាក់ទំនង ដោយផ្អែកលើកិច្ចព្រមព្រៀង ឬការរៀបចំទ្វេភាគី រវាងបណ្តាភាគីដែលពាក់ព័ន្ធ ។

ង-ផ្លាស់ប្តូរព័ត៌មានជាមួយបណ្តាភាគីផ្សេងទៀត ស្តីពីមធ្យោបាយ និងវិធីសាស្ត្រជាក់លាក់ ដែលប្រើប្រាស់

ដោយពួកជួញដូរ បើសិនជាអាចធ្វើទៅបាន ក្នុងនោះរួមមានទាំងផ្លូវធ្វើដំណើរ និងមធ្យោបាយដឹកនាំ និងការប្រើអត្តសញ្ញាណក្លែងក្លាយ ឯកសារកែ ឬក្លែងបន្លំ ឬមធ្យោបាយផ្សេងទៀតដើម្បីបិទបាំងអំពីសកម្មភាពរបស់ពួកគេ ។

**ច**-ផ្លាស់ប្តូរព័ត៌មាន និងសម្របសម្រួលការចាត់បណ្តាវិធានការរដ្ឋបាល និងបណ្តាវិធានការផ្សេងទៀតឱ្យបានសមស្រប ក្នុងគោលបំណងកំណត់បទល្មើសដូចមានចែងនៅក្នុងអនុសញ្ញានេះឱ្យបានឆាប់ ។

**២**-ដើម្បីអនុវត្តអនុសញ្ញានេះឱ្យមានប្រសិទ្ធិភាព ភាគីទាំងអស់ត្រូវពិចារណាដល់ការចុះកិច្ចព្រមព្រៀង ឬការរៀបចំផ្សេងៗជាទ្វេភាគី ស្តីពីកិច្ចសហប្រតិបត្តិការផ្ទាល់រវាងបណ្តាទីភ្នាក់ងារអនុវត្តច្បាប់ ហើយប្រសិនបើកិច្ចព្រមព្រៀង ឬ ការរៀបចំរបៀបនេះមានស្រាប់ហើយ គឺគ្រាន់តែធ្វើវិសោធនកម្មជាការស្រេច ។ ក្នុងករណីដែលគ្មានកិច្ចព្រមព្រៀង ឬ ការរៀបចំរបៀបនេះរវាងបណ្តាភាគីពាក់ព័ន្ធទេ ភាគីទាំងអស់អាចពិចារណាយកអនុសញ្ញានេះធ្វើជាមូលដ្ឋានសម្រាប់កិច្ចសហប្រតិបត្តិការផ្នែកអនុវត្តច្បាប់ទៅវិញទៅមក ទាក់ទងនឹងបទល្មើសដែលមានចែងនៅក្នុងអនុសញ្ញានេះ ។នៅពេលដែលមានឱកាសសមស្រប បណ្តាភាគីត្រូវប្រើប្រាស់កិច្ចព្រមព្រៀង ឬការរៀបចំទាំងនេះឱ្យអស់លទ្ធភាព ក្នុងនោះរួមទាំងបណ្តាអង្គការអន្តរជាតិ ឬ តំបន់ដើម្បីលើកកំពស់កិច្ចសហប្រតិបត្តិការរវាងបណ្តាទីភ្នាក់ងារអនុវត្តច្បាប់របស់ខ្លួន ។

**៣**-បណ្តាភាគីទាំងអស់ត្រូវខិតខំខ្នះខ្នែងធ្វើសហប្រតិបត្តិការតាមមធ្យោបាយដែលខ្លួនមាន ដើម្បីឆ្លើយតបទៅនឹងឧក្រិដ្ឋកម្មឆ្លងដែនដែលមានអង្គការចាត់តាំងដែលបានកើតឡើងតាមរយៈការប្រើប្រាស់បច្ចេកទំនើប ។

## មាត្រា ២១

## កិច្ចសហប្រតិបត្តិការអន្តរជាតិក្នុងគោលបំណងរឹបអូស

**១**-ភាគីមួយដែលបានទទួលសំណើពីភាគីមួយទៀត ជាអ្នកមានយុត្តាធិការលើបទល្មើសមួយដែលមានចែងនៅក្នុងអនុសញ្ញានេះ ដើម្បីធ្វើការរឹបអូសផលចំណូលនៃបទល្មើសទ្រព្យសម្បត្តិ សំភារៈ ឬគ្រឿងឧបករណ៍ផ្សេងទៀតដែលស្ថិតនៅក្នុងដែនដីរបស់ខ្លួន-យោងតាមមាត្រា ១៧ កថាខ័ណ្ឌ១ នៃអនុសញ្ញានេះ និងតាមលទ្ធភាពទាំងអស់ដែលប្រព័ន្ធច្បាប់របស់ប្រទេសខ្លួនអនុញ្ញាតឱ្យ ត្រូវៈ

ក-ដាក់សំណើជូនអាជ្ញាធរមានសមត្ថកិច្ចរបស់ខ្លួន ក្នុងគោលបំណងស្នើសុំដីការឹបអូស ពេលទទួលបានដីកាហើយ ត្រូវអនុវត្តដីកានោះឱ្យមានប្រសិទ្ធិភាព ឬ

ខ-បញ្ជូនទៅអាជ្ញាធរមានសមត្ថកិច្ចរបស់ខ្លួននូវដីការឹបអូស ដែលចេញដោយតុលាការនៅក្នុងដែនដីនៃភាគីដាក់សំណើស្របតាមមាត្រា១៧ កថាខ័ណ្ឌ១ នៃអនុសញ្ញានេះ តាមអំណាចដែលដីកាមានទាក់ទងនឹងផលចំណូលនៃបទល្មើស ទ្រព្យសម្បត្តិ សំភារៈ ឬ គ្រឿងឧបករណ៍ផ្សេងទៀតដែលស្ថិតនៅក្នុងដែនដីនៃភាគីទទួលសំណើ ក្នុងគោលបំណងអនុវត្តដីកាឱ្យមានប្រសិទ្ធិភាពតាមការស្នើសុំដោយយោងតាមមាត្រា ១៧ កថាខ័ណ្ឌ ១ ។

២-បន្ទាប់ពីមានសំណើធ្វើឡើងដោយភាគីមួយទៀត ដែលមានយុត្តាធិការលើបទល្មើសដូចមានចែងនៅក្នុងអនុសញ្ញានេះ ភាគីទទួលសំណើត្រូវចាត់វិធានការនានាដើម្បីស្វែងរក តាមដាន និងរឹបអូស ឬ ដកហូតផលចំណូលនៃបទល្មើស ទ្រព្យសម្បត្តិ សំភារៈ ឬ គ្រឿងឧបករណ៍ផ្សេងទៀត ដោយយោងតាមមាត្រា១៧ កថាខ័ណ្ឌ១នៃអនុសញ្ញានេះ ក្នុងគោលបំណងសំរាប់រឹបអូសជាយថាហេតុតាមដីកាដែលចេញដោយភាគីដាក់សំណើផង និងយោងតាមសំណើធ្វើឡើងដោយភាគីទទួលសំណើផង ដូចមានចែងនៅក្នុងកថាខ័ណ្ឌ ១នៃមាត្រានេះ ។

៣-បទបញ្ញត្តិទាំងឡាយនៅក្នុងមាត្រា ១៨នៃអនុសញ្ញានេះ អាចយកមកអនុវត្តបានជាមួយមាត្រានេះ បើមានការចាំបាច់ ។ ក្រៅពីព័ត៌មានបញ្ជាក់ជូននៅក្នុងមាត្រា ១៨នេះ សំណើទាំងឡាយដែលធ្វើឡើងយោងតាមមាត្រានេះត្រូវរួមមាន :

ក-ក្នុងករណីដែលសំណើទាក់ទងនឹងកថាខ័ណ្ឌ១(ក)នៃមាត្រានេះ ត្រូវពិពណ៌នាអំពីទ្រព្យសម្បត្តិដែលត្រូវរឹបអូស សេចក្ដីថ្លែងអំពីអង្គហេតុមានន័យគ្រប់គ្រាន់ដែលភាគីដាក់សំណើយកធ្វើជាសំអាងដើម្បីផ្ដល់លទ្ធភាពឱ្យភាគីទទួលសំណើស្នើសុំដីកាយោងតាមច្បាប់របស់ប្រទេសខ្លួន ។

ខ-ក្នុងករណីដែលសំណើទាក់ទងនឹងកថាខ័ណ្ឌ ១(ខ)នៃមាត្រានេះ ត្រូវមានដីការឹបអូសមួយច្បាប់ ដែលទទួលស្គាល់តាមផ្លូវច្បាប់ ដែលភាគីដាក់សំណើយកធ្វើជាមូលដ្ឋានក្នុងការធ្វើសំណើ សេចក្ដីថ្លែងអំពីអង្គហេតុ និងព័ត៌មានទាក់ទងនឹងវិសាលភាពនៃសំណើសុំឱ្យអនុវត្តដីកានោះ

គ-ក្នុងករណីដែលសំណើទាក់ទងនឹងកថាខ័ណ្ឌ២នៃមាត្រានេះ
ត្រូវមានសេចក្ដីថ្លែងអំពីអង្គហេតុដែលភាគី ដាក់សំណើយកធ្វើជាសំអាងក្នុងការធ្វើសំណើ

និងការពិពណ៌នាអំពីចំណាត់ការដែលបានស្នើឡើង។

៤-រាល់សេចក្តីសម្រេច ឬ ចំណាត់ការនានាដែលមានចែងនៅក្នុងកថាខ័ណ្ឌ១ និង ២ នៃមាត្រានេះនឹងត្រូវអនុវត្ត ដោយភាគីទទួលសំណើដោយអនុលោម និងយោងតាមបទបញ្ញត្តិទាំងឡាយនៃច្បាប់របស់ប្រទេសខ្លួន និង ក្បួននីតិវិធីរបស់ខ្លួន ឬ សន្ធិសញ្ញាទ្វេភាគី ដែលជាកាតព្វកិច្ចទាក់ទងនឹងភាគីដាក់សំណើ ឬ សន្ធិសញ្ញា ស្តីពីជំនួយផ្នែកច្បាប់ទៅវិញទៅមក។

៥-ប្រសិនបើភាគីមួយសម្រេចថា ការចាត់វិធានការយោងតាមកថាខ័ណ្ឌ១ និង២នៃមាត្រានេះមានលក្ខខ័ណ្ឌ ដោយផ្អែកលើអត្ថិភាពនៃអនុសញ្ញាពាក់ព័ន្ធ អញ្ចឹងភាគីនោះត្រូវចាត់ទុកថាអនុសញ្ញានេះជាមូលដ្ឋានសន្ធិសញ្ញាដែលមានលក្ខណៈចាំបាច់ និងគ្រប់គ្រាន់។

៦-បទបញ្ញត្តិទាំងឡាយនៃមាត្រានេះ នឹងមិនត្រូវចាត់ទុកថា មានការប៉ះពាល់ដល់សិទ្ធិដែលប្រកបដោយសុចរិតភាពរបស់ភាគីទីបីឡើយ។

៧-ភាគីទាំងអស់ត្រូវធ្វើការពិចារណាដើម្បីសម្រេចនូវបណ្តាសន្ធិសញ្ញា កិច្ចព្រមព្រៀង ឬ ការរៀបចំទាំងឡាយ ទាំងទ្វេភាគី ឬ ពហុភាគីដើម្បីលើកកំពស់ប្រសិទ្ធិភាពនៃការអនុវត្តកិច្ចសហប្រតិបត្តិការអន្តរជាតិដែលនឹងត្រូវធ្វើឡើងអនុលោមតាមមាត្រានេះ។

## មាត្រា ១២

## ការចាត់ចែងលើផលចំណូលនៃបទល្មើស និង ទ្រព្យសម្បត្តិដែលបានរឹបអូស

១-ផលចំណូលនៃបទល្មើស ឬ ទ្រព្យសម្បត្តិដែលត្រូវរឹបអូសដោយភាគីមួយ យោងតាមមាត្រា១៧ ឬ មាត្រា ២១ កថាខ័ណ្ឌ១ នៃអនុសញ្ញានេះ នឹងត្រូវបានចាត់ចែងដោយភាគីនោះ អនុលោមតាមច្បាប់ប្រទេស និង នីតិវិធីរដ្ឋបាលរបស់ខ្លួន។

**២**-នៅពេលដែលចាត់វិធានការតាមសំណើដែលធ្វើឡើងដោយភាគីមួយទៀត អនុលោមតាមមាត្រា ២១ នៃអនុសញ្ញានេះ ភាគីទាំងឡាយ-តាមលទ្ធភាពដែលច្បាប់របស់ប្រទេសខ្លួនអនុញ្ញាត្ត ហើយប្រសិនបើមានការស្នើសុំដូច្នេះមែន ត្រូវធ្វើការពិចារណាផ្តល់អាទិភាពដល់ការបញ្ជូនផលចំណូលនៃបទល្មើស ឬ ទ្រព្យសម្បត្តិទាំងនោះត្រឡប់ទៅភាគីដាក់សំណើវិញ ដើម្បីឱ្យរដ្ឋនោះមានលទ្ធភាពផ្តល់សំណង និងជំនួយដល់ជនរងគ្រោះដោយអំពើជួញដូរមនុស្ស ឬ បញ្ជូនផលចំណូលនៃបទល្មើស ឬ ទ្រព្យសម្បត្តិទាំងនោះត្រឡប់ទៅឱ្យម្ចាស់ស្របច្បាប់វិញ។

**៣**-នៅពេលចាត់វិធានការតាមសំណើ ដែលធ្វើឡើងដោយភាគីមួយទៀត អនុលោមតាមមាត្រា២១ នៃអនុសញ្ញានេះ ភាគីមួយអាចធ្វើការពិចារណាជាពិសេសលើការសម្រេចកិច្ចព្រមព្រៀង ឬ ការរៀបចំទាំងឡាយ ស្តីពីការចែករំលែកជាមួយបណ្តាភាគីផ្សេងទៀត ទៅតាមពេលវេលាទៀងទាត់ ឬ ផ្អែកលើករណីនីមួយៗ នូវផលចំណូលនៃបទល្មើស ឬ ទ្រព្យសម្បត្តិ ឬ មូលនិធិដែលបានមកពីការលក់ផលចំណូលនៃបទល្មើស ឬ ទ្រព្យសម្បត្តិទាំងនោះ អនុលោមតាមច្បាប់ប្រទេស និង នីតិវិធីរដ្ឋបាលរបស់ខ្លួន។

## ជំពូក VII

## អវសានប្បញ្ញត្តិ

### មាត្រា ២៣

### ការបង្កើតរចនាសម្ព័ន្ធសម្របសម្រួល

ភាគីនីមួយៗត្រូវពិចារណាបង្កើតឡើងនូវរចនាសម្ព័ន្ធសម្របសម្រួលក្នុងការប្រយុទ្ធប្រឆាំងនឹងអំពើជួញដូរមនុស្ស រួមទាំងលើកកំពស់កិច្ចសហប្រតិបត្តិការលើគ្រប់ផ្នែកដែលមានចែងនៅក្នុងអនុសញ្ញានេះ។

### មាត្រា ២៤

### ការតាមដាន ការពិនិត្យមើលឡើងវិញ និង ការរាយការណ៍

១-កិច្ចប្រជុំឧត្តមមន្ត្រីអាស៊ាន ស្តីពី ឧក្រិដ្ឋកម្មឆ្លងដែន(**SOMTC**)ត្រូវទទួលខុសត្រូវក្នុងការជុំរុញ តាមដាន

ពិនិត្យមើលឡើងវិញ និងធ្វើរបាយការណ៍តាមកាលកំណត់ជូនកិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រីអាស៊ាន ស្តីពី ឧក្រិដ្ឋកម្មឆ្លងដែន **(AMMTC)** ស្តីពីប្រសិទ្ធិភាពនៃការអនុវត្តអនុសញ្ញានេះ ។

**២**-លេខាធិការដ្ឋានអាស៊ានត្រូវផ្តល់ការគាំទ្រដល់ការតាមឃ្លាំមើល និង សម្របសម្រួលការអនុវត្តអនុសញ្ញានេះ និង ជួយដល់កិច្ចប្រជុំឧត្តមមន្ត្រីអាស៊ាន ស្តីពីឧក្រិដ្ឋកម្មឆ្លងដែន(**SOMTC**)នូវរាល់បញ្ហាដែលទាក់ទងនឹងអនុសញ្ញានេះ ។

## មាត្រា ២៥

## ការរក្សាការសំងាត់នៃឯកសារ របាយការណ៍ និង ព័ត៌មាន

**១**-ភាគីនីមួយៗត្រូវរក្សាការសំងាត់ និង អាថិកំបាំងនៃឯកសាររបាយការណ៍ និង ព័ត៌មានផ្សេងទៀតដែលទទួលបានមកពីភាគីផ្សេងៗ រួមទាំងប្រភពនៃព័ត៌មាននោះផងដែរ ។

**២**-អនុលោមតាមអនុសញ្ញានេះ ការបញ្ចេញ ឬ ការចែករំលែកឯកសារ របាយការណ៍ ឬ ព័ត៌មានផ្សេងៗដែលទទួលបានមកទៅឱ្យភាគី រដ្ឋ ឬ បុគ្គលផ្សេងទៀត មិនត្រូវបានអនុញ្ញាតឡើយ លើកលែងតែមានការយល់ព្រមជាលាយលក្ខអក្សរជាមុនពីភាគីដែលផ្តល់ឯកសារ របាយការណ៍ ឬ ព័ត៌មានទាំងនេះ ។

## មាត្រា ២៦

## ទំនាក់ទំនងជាមួយនឹងបណ្តាលិខិតុបករណ៍អន្តរជាតិផ្សេងទៀត

អនុសញ្ញានេះមិនបានដកហូតកាតព្វកិច្ចនានា ដែលនៅជាធរមានរវាងបណ្តាភាគីទាំងអស់ អនុលោមតាមកិច្ចព្រមព្រៀងអន្តរជាតិផ្សេងទៀតរបស់ពួកគេ និងក៏មិនបានហាមឃាត់ភាគីទាំងអស់ពីការផ្តល់ជំនួយឱ្យគ្នាទៅវិញទៅមកដែរ អនុលោមតាមបណ្តាកិច្ចព្រមព្រៀងអន្តរជាតិផ្សេងទៀត ឬ បណ្តាបទបញ្ញត្តិនៃច្បាប់ប្រទេសដែលពួកគេបានព្រមព្រៀងរៀងៗខ្លួន ។

## មាត្រា ២៧

## ការដោះស្រាយវិវាទ

រាល់ការខ្វែងគំនិតគ្នា ឬ វិវាទរវាងបណ្តាភាគីដែលកើតចេញពីការបកស្រាយ ឬ ការអនុវត្តបណ្តាបទបញ្ញត្តិនៃអនុសញ្ញានេះ នឹងត្រូវបានដោះស្រាយដោយមេត្រីភាព តាមរយៈការពិគ្រោះយោបល់ និងការចរចារ

រវាងបណ្តាភាគីតាមប្រព័ន្ធការទូត ឬ តាមរយៈមធ្យោបាយដោយសន្តិវិធីផ្សេងទៀតដើម្បីដោះស្រាយវិវាទតាមដែលភាគីទាំងអស់បានព្រមព្រៀងគ្នា។

## មាត្រា ២៨

## ការផ្តល់សច្ចាប័ន ការអនុម័ត និងកន្លែងតម្កល់ទុក

អនុសញ្ញានេះត្រូវទទួលបានការផ្តល់សច្ចាប័ន ឬ ការអនុម័ត អនុលោមតាមនីតិវិធីផ្ទៃក្នុងរបស់ភាគីទាំងអស់។បន្ទាប់ពីទទួលបានការផ្តល់សច្ចាប័ន និងការអនុម័តរួច លិខិតុបករណ៍នេះនឹងត្រូវដាក់តម្កល់ទុកនៅជាមួយនឹងអគ្គលេខាធិការអាស៊ាន ជាអ្នកដែលត្រូវជូនដំណឹងបន្ទាន់ឱ្យបណ្តាភាគីផ្សេងៗបានជ្រាបពីការតម្កល់ទុកនេះ។

## មាត្រា ២៩

## ការចូលជាធរមាន និង វិសោធនកម្ម

**១**-អនុសញ្ញានេះត្រូវចូលជាធរមាននៅក្នុងរយៈពេល៣០ (សាមសិប) ថ្ងៃបន្ទាប់ពីកាលបរិច្ឆេទនៃការតម្កល់ទុកលិខិតុបករណ៍ដែលបានទទួលការផ្តល់សច្ចាប័ន ឬ ការអនុម័តចំនួន០៦ច្បាប់ ពីភាគីទាំងឡាយដែលបានបញ្ជូនលិខិតុបករណ៍ដែលពួកគេបានផ្តល់សច្ចាប័ន ឬ ផ្តល់ការអនុម័តរួចមកអគ្គលេខាធិការអាស៊ាន។

**២**-ចំពោះភាគីដែលផ្តល់សច្ចាប័ន ឬ អនុម័តលើអនុសញ្ញានេះ នៅក្រោយការដាក់តម្កល់លិខិតុករណ៍ដែលបានផ្តល់សច្ចាប័ន ឬ ការអនុម័តរួចបានចំនួន ០៦ច្បាប់ ក៏ប៉ុន្តែនៅមុនថ្ងៃដែលសន្ធិសញ្ញាចូលជាធរមាន អនុសញ្ញានេះក៏នឹងមានប្រសិទ្ធិភាពចំពោះភាគីនោះដែរ នៅថ្ងៃដែលអនុសញ្ញាបានចូលជាធរមាន។ ចំពោះភាគីដែលផ្តល់សច្ចាប័ន ឬ ផ្តល់ការអនុម័តលើអនុសញ្ញានេះបន្ទាប់ពីអនុសញ្ញាចូលជាធរមានរួច អនុលោមតាមកថាខ័ណ្ឌ១ នោះអនុសញ្ញានឹងចូលជាធរមានសំរាប់ភាគីនោះ តាមកាលបរិច្ឆេទដែលលិខិតុបករណ៍ទទួលបានការផ្តល់សច្ចាប័ន ឬការអនុម័តនោះត្រូវបានយកមកដាក់តម្កល់ទុក។

**៣**-អនុសញ្ញានេះអាចមានការកែប្រែ និងធ្វើវិសោធនកម្មបានគ្រប់ពេល តាមរយៈការព្រមព្រៀងជាលាយលក្ខអក្សរទៅវិញទៅមករបស់ភាគីទាំងអស់។ ការកែប្រែ ឬ វិសោធនកម្មទាំងនេះនឹងត្រូវចូលជាធរមានទៅតាមកាលបរិច្ឆេទដែលភាគីទាំងអស់ព្រមព្រៀងគ្នា ដែលការព្រមព្រៀងនេះនឹងក្លាយជាផ្នែកមួយនៃអនុសញ្ញានេះ។

**៤**-រាល់ការកែប្រែ ឬ វិសោធនកម្មទាំងឡាយនឹងមិនមានការប៉ះពាល់ដល់សិទ្ធិ និងកាតព្វកិច្ចរបស់ភាគីទាំងអស់ដែលកើតចេញពី ឬ ផ្អែកលើបណ្តាបទបញ្ញត្តិនៃអនុសញ្ញានេះឡើយ មុនពេលដែលការកែប្រែ ឬ វិសោធនកម្មទាំង

នេះចូលជាធរមាននោះ ។

## មាត្រា ៣០

## ការដកខ្លួនចេញពីអនុសញ្ញា

១-ភាគីទាំងឡាយអាចដកខ្លួនពីអនុសញ្ញានេះបានគ្រប់ពេល ក្រោយពីកាលបរិច្ឆេទដែលអនុសញ្ញានេះចូលជាធរមានសំរាប់ភាគីនោះ ។

**២-អគ្គលេខាធិការអាស៊ាន**នឹងបានជ្រាបពីការដកខ្លួនចេញនេះនឹងតាមរយៈលិខិតជូនដំណឹង ស្តីពីការសុំដកខ្លួននេះ ។

**៣**-ការសុំដកខ្លួននឹងត្រូវចូលជាធរមានក្នុងរយៈពេល ១៨០ថ្ងៃ (មួយរយប៉ែតសិបថ្ងៃ) បន្ទាប់ពី**អគ្គលេខាធិការអាស៊ាន**បានទទួលលិខិត ស្តីពីការសុំដកខ្លួននេះ ។

**៤-អគ្គលេខាធិការអាស៊ាន**ត្រូវជម្រាបជូនដំណឹងជាបន្ទាន់ឱ្យបណ្តាភាគីផ្សេងទៀតបានជ្រាបពីការសុំដកខ្លួននេះ ។

## មាត្រា ៣១

## ការចុះញី

**អគ្គលេខាធិការអាស៊ាន**នឹងយកអនុសញ្ញានេះទៅចុះបញ្ជីនៅឯ**លេខាធិការដ្ឋានសហប្រជាជាតិ** អនុលោមតាមមាត្រា **១០២** នៃធម្មនុញ្ញ**របស់សហប្រជាជាតិ** ។

***ធ្វើនៅប្រទេសភីលីពីន*** **ថ្ងៃទី ខែ មេសា ឆ្នាំ ពីរពាន់ ......... មានច្បាប់ដើមជាភាសាអង់គ្លេសតែមួយច្បាប់គត់ ។**

**សំរាប់ប្រទេសព្រុយណេដារូស្សាឡឹម:**

**(ឈ្មោះជាអក្សរធំ)**

**(តួនាទី)**

សំរាប់ព្រះរាជាណាចក្រកម្ពុជា៖

(ឈ្មោះជាអក្សរធំ)

(តួនាទី)

សំរាប់សាធារណរដ្ឋឥណ្ឌូណេស៊ី៖

(ឈ្មោះជាអក្សរធំ)

(តួនាទី)

សំរាប់សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ៖

(ឈ្មោះជាអក្សរធំ)

(តួនាទី)

សំរាប់ម៉ាឡេស៊ី៖

(ឈ្មោះជាអក្សរធំ)

(តួនាទី)

សំរាប់សាធារណរដ្ឋសហភាពមីយ៉ាន់ម៉ា៖

(ឈ្មោះជាអក្សរធំ)

(តួនាទី)

សំរាប់សាធារណរដ្ឋភីលីពីន៖

(ឈ្មោះជាអក្សរធំ)

(តួនាទី)

សំរាប់សាធារណរដ្ឋសឹង្ហបូរី៖

(ឈ្មោះជាអក្សរធំ)

(តួនាទី)

សំរាប់ព្រះរាជាណាចក្រថៃ៖

(ឈ្មោះជាអក្សរធំ)

(តួនាទី)

សំរាប់សាធារណរដ្ឋសង្គមនិយមវៀតណាមៈ

(ឈ្មោះជាអក្សរធំ)

(តួនាទី)